# ជំពូកទី ៨

## ៨. ផែនការគ្រប់គ្រងបរិស្ថាន (EMP)

ផែនការគ្រប់គ្រងបរិស្ថាន (EMP) ផ្តល់ជាមគ្គុទេសសំរាប់ត្រួតពិនិត្យតាមដាន និងមានវិធានការបន្ធូរបន្ថយសំរាប់ការអនុវត្តន៏មុនពេលសាងសង់ ពេលសាងសង់ និង ពេលប្រតិបត្តិការគំរោង ។ EMP រួមមាន ការរៀបចំស្ថាប័ន សង្ខេបវិធានការបន្ធូរបន្ថយ និង កម្មវិធីពិនិត្យតាមដាន។ វិធានការបន្ធូរបន្ថយ និង កម្មវិធីតាមដាន នឹងរាប់បញ្ចូលនូវកាលវិភាគ ស្ថាប័នទទួលខុសត្រូវ និង ថវិកា។

### *៨.១ ការរៀបចំស្ថាប័ន*

ការអនុវត្តន៏ EMP សំរាប់គំរោងនឹងអនុវត្តដោយម្ចាស់គំរោង ដោយសហការជាមួយស្ថាប័នជំនាញដូចជាអគ្គនាយកដ្ឋានថាមពល (GDE) នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល (MIME), មន្ទីរបរិស្ថានខេត្ត (PDoE), ខណ្ឌរដ្ឋបាលព្រៃឈើ, ខណ្ឌរដ្ឋបាលជលផល មន្ទីរធនធានទឹក និងឧតុនិយមខេត្ត (PDWRAM), បណ្តាញទន្លេ ៣S និង សមាគមន៏ការពារវប្បធម៌បរិស្ថាន (CEPA) (ជាអង្គការក្រៅរដ្ឋាភិបាលនៅខេត្តស្ទឹងត្រែង), មន្ទីររៀបចំដែនដីនិងនគររូបនីយកម្មខេត្ត (PDLMUPC), មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត, អាជ្ញាធរដែនដី ជាពិសេសក្រុមប្រឹក្សាស្រុក/ឃុំ, គណៈកម្មការអន្តរក្រសួងសំរាប់រៀបចំទីលំនៅសារជាថ្មី (IRC), និង ពីថ្នាក់កណ្តាល ដែលនឹងសហការជាមួយក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល (MIME), នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុលរបស់ក្រសួងបរិស្ថាន (MoE), រដ្ឋបាលព្រៃឈើ និង រដ្ឋបាលជលផលរបស់ក្រសួងកសិកម្មរុក្ខប្រមាញ់ និង នេសាទ (MAFF), នាយកដ្ឋានជលសាស្ត្រ និងកិច្ចការទន្លេរបស់ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ។

ម្ចាស់គំរោង ក្រុមហ៊ុនសាងសង់ និងប្រតិបត្តិ (វិស្វករប្លង់ និង វិស្វករប្រតិបត្តិរបស់ម្ចាស់គំរោង) មានការទទួលខុសត្រូវទាំងស្រុងដើម្បីធានាថា គ្រប់សកម្មភាពសាងសង់ និងប្រតិបត្តិទាំងអស់ដែលនឹងបង្កគ្រោះថ្នាក់ដល់ធនធានបរិស្ថាន និងសង្គម ត្រូវធ្វើទៅតាមបទដ្ឋានបរិស្ថាននៅក្នុង EMP សំរាប់គំរោង។ ការត្រួតពិនិត្យ និងតាមដានប្រចាំថ្ងៃប្រចាំសប្តាហ៏ និង/ឬប្រចាំខែ នៅក្នុងនិងជុំវិញតំបន់គំរោង នៅដំណាក់កាលសាងសង់ និងប្រតិបត្តិ ជាតំរូវការដើម្បីអោយប្រាកដថាអ្នកម៉ៅការប្រព្រឹត្តិទៅតាមប្លង់វិស្វកម្ម និង ការងារប្រតិបត្តិ និង តាម EMP។ ចំនុចនេះនឹងចាំបាច់ត្រូវដាក់បញ្ចូលជាលក្ខខណ្ឌនៅក្នុងឯកសារនៃកិច្ចសន្យាសាងសង់។

អ្នកមៅការត្រូវទទួលខុសត្រូវការងារអនុវត្តប្រចាំថ្ងៃតាមផែនការ EMP និង ការការពារបរិស្ថានផ្សេងទៀត ដែលមានក្រើនរំលឹកនៅក្នុងឯកសារនៃកិច្ចសន្យាសាងសង់ដើម្បីធានាបានរាល់សកម្មភាពសាងសង់ និងប្រតិបត្តិការ គោរពទៅតាមបទដ្ឋានការពារបរិស្ថាន។

Draft

ម្ចាស់គំរោង/អ្នកវិនិយោគគំរោង ត្រូវទទួលខុសត្រូវរាល់ចំណាយទាំងអស់សំរាប់សំណងលើផលប៉ះពាល់ទាំងអស់ តំលៃសំរាប់វិធានការបន្ធូរបន្ថយបរិស្ថាន និង ពិនិត្យតាមដាន ក្នុងរយៈពេលនៃការធ្វើវិនិយោគគំរោងទាំងមូល ។ គេទាមទារអោយមានការធ្វើសហប្រតិបត្តិការ និងការសហការយ៉ាងល្អជាមួយជនឬស្ថាប័នដែលជាប់ទាក់ទងគំរោង ដើម្បីធានាបាននៅរាល់ដំណាក់កាលនៃការអនុវត្តន៏គំរោងទាំងអស់ប្រព្រឹត្តិទៅយ៉ាងរលូន និងជោគជ័យ ។

នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន (DEIA) និង នាយកដ្ឋានត្រួតពិនិត្យការបំពុលរបស់ក្រសួងបរិស្ថាន មានភារៈកិច្ចលើការពិនិត្យអង្កេត និង តាមដាននូវរាល់ហេតុប៉ះពាល់បរិស្ថានទាំងអស់ដែលកើតឡើងនៅក្នុងបរិវេណគំរោង ក៏ដូចជានៅក្នុងតំបន់នោះ។ តំរូវអោយមានការត្រួតពិនិត្យ និង តាមដានប្រចាំខែ និងប្រចាំឆ្នាំ ឬការឆែកមើលជាបន្ទាន់ផងដែរ ។ ការគ្រប់គ្រងគុណភាពបរិស្ថាន និង ការណែនាំពីទំរង់ការបន្ធូរបន្ថយ គួរផ្តល់អោយម្ចាស់គំរោង ក៏ដូចជាភ្នាក់ងារសាងសង់ និងភ្នាក់ងារប្រតិបត្តិគំរោង ដើម្បីធ្វើអោយប្រាកដថាគ្មានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរកើតឡើងនៅក្នុងតំបន់គំរោងនោះទេ។

គណៈកម្មការអន្តរក្រសួងសំរាប់រៀបចំការតាំងទីលំនៅសារជាថ្មី (IRC) របស់ MEF រួមជាមួយបណ្ដាក្រសួងនានា និង អាជ្ញាធរមូលដ្ឋាន ជាអ្នកទទួលខុសត្រូវចំពោះការអនុម័ត លើផែនការសកម្មភាពសំរាប់ការតាំងទីលំនៅសារជាថ្មី និងអត្រាសំណង ដោយរួមសហប្រតិបត្តិការជាមួយម្ចាស់គំរោងក្នុងការផ្លាស់ប្តូរទី និងការតាំងទីលំនៅសារជាថ្មីរបស់ប្រជាជានដែលបានទទួលផលប៉ះពាល់ (AP) ដោយសកម្មភាពគំរោង ហើយជួយដល់ម្ចាស់គំរោងដោះស្រាយ និង អនុវត្តតាមគោលនយោបាយរបស់រដ្ឋាភិបាល អត្រាសំណង និងទំរង់ការនៃផែនការសកម្មភាពនៃការតាំងទីលំនៅសារជាថ្មី ។ IRC នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរៀបចំដែនដី និងនគររូបនីយកម្ម និងជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធានាបានថាសំណងធ្វើបានត្រឹមត្រូវ និង អាចទទួលយកបានដោយ APs ។

Draft

រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និង ភ្នាក់ងារអភិរក្សផ្សេងៗទៀតនៅក្នុងតំបន់គំរោង មានភារៈកិច្ចទទួលខុសត្រូវចំពោះការធ្វើអធិការកិច្ច និងពិនិត្យតាមដានផលប៉ះពាល់លើវារីសត្វ និង សត្វព្រៃ ឬរុក្ខជាតិ លើគោកនៅក្នុងតំបន់គំរោង ។

អាជ្ញាធរតំបន់ និងនគរបាល មានភារៈទទួលខុសត្រូវសំរបសំរួល ត្រួតពិនិត្យ និងដោះស្រាយ ជម្លោះសង្គមដែលកើតឡើងនៅក្នុងតំបន់គំរោង ។ ពួកគេនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយម្ចាស់គំរោង ដើម្បីទប់ស្កាត់ចរាចរថ្នាំញៀន និង សកម្មភាពខុសច្បាប់ផ្សេងទៀតក្នុងតំបន់គំរោង ។

## ៨.២ សង្ខេបផលនៃហេតុប៉ះពាល់បរិស្ថាន និង វិធានការបន្ធូរបន្ថយ

គំរោងនឹងប៉ះពាល់ដល់ធនធានធម្មជាតិនិងសង្គម នៅក្នុងនិងនៅជុំវិញតំបន់គំរោងអាស្រ័យទៅតាមសកម្មភាពគំរោងមុនពេលសាងសង់ ពេលសាងសង់ និង ប្រតិបត្តិការ។ វិធានការបន្ធូរបន្ថយដែលបានស្នើឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ដែលបានកំណត់សំរាប់ផ្នែកបរិស្ថាននិមួយៗនៅក្នុងដំណាក់កាលផ្សេងគ្នារបស់គំរោង មានសង្ខេបនៅក្នុងតារាងទី ៥៨។

**តារាងទី ៥៨:** សង្ខេបពីហេតុប៉ះពាល់បរិស្ថាន និង វិធានការបន្ធូរបន្ថយដែលបានស្នើឡើង

| បញ្ហា | សក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន | កំរិតនៃហេតុប៉ះពាល់ | | | វិធានការបន្ធូរបន្ថយដែលបានស្នើ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | | |
| *A- ដំណាក់កាលមុនសាងសង់* | | | | | | | |
| ទីតាំងគំរោង | តំបន់អាងស្តុកទឹកនឹងត្រូវលិចលង់ដីកសិកម្ម តំបន់ព្រៃឈើ វាលស្មៅ ព្រៃល្បោះ និងដីប្រើប្រាស់ផ្សេងទៀតនៅក្នុងស្រុកសេសាន។ តំបន់តាំងទីលំនៅសារជាថ្មី នឹងត្រូវប៉ះពាល់ផងដែរលើដីព្រៃឈើ។ តំបន់អាងស្តុកទឹក និងតំបន់តាំងទីលំនៅសារជាថ្មី ដែលបានស្នើសុំនឹងគ្របដណ្តប់លើដីសម្បទាន និង ព្រៃសម្បទានមួយចំនួននៅក្នុងស្រុកសេសាន។ ជាងនេះទៅទៀត តំបន់គំរោងក៏មានហានិភ័យផងដែរជាមួយការរញ្ជួយដីតាមលក្ខណៈភូគព្ភសាស្ត្រក្នុងតំបន់។ | | ✓ | | - បន្ថយទំហំអាងដោយកាត់បន្ថយកំពស់ទំនប់ ដោយកំរិត កំពស់ទឹកនៅក្នុងអាងមិនលើពី ៧៥ម ដើម្បីកាត់បន្ថយអោយបានជាអប្បបរិមាតំបន់ព្រៃឈើ ដីកសិកម្ម ដីសម្បទាន និង តំបន់លំនៅដ្ឋានដែលមានរបស់ឃុំទាំងបួន ក្នុងស្រុកសេសាន។<br>- ទីតាំងទំនប់គួរសាងសង់នៅទីតាំងជំរើសទី ១ ចំងាយ ១.៥ គ.ម ខាងក្រោមខ្សែទឹកពីចំនុចប្រសព្វរបស់ទន្លេសេសាន និង ទន្លេ ស្រែពក។<br>- តំបន់តាំងទីលំនៅសារជាថ្មីគួរមានទីតាំងនៅកន្លែងដែលគ្មានជម្លោះ ឬបង្កគ្រោះថ្នាក់ដល់ធនធានសង្គម និងបរិស្ថាន នៅក្នុងតំបន់។<br>- ការរៀបចំប្លង់ នឹងរួមបញ្ចូលការការពាររញ្ជួយដីក្នុងតំបន់គំរោង។ ការធ្វើផែនការ និងការរៀបចំគំរោងថវិកា គឺជាការចាំបាច់ សំរាប់ជំនួយសង្គ្រោះបន្ទាន់ដល់អ្នករង គ្រោះប្រសិនបើបញ្ហានេះកើតឡើង។ | DE/PO, និង GDE | គ្មាន (DE/PO ជាអ្នកទទួលខុសត្រូវ) |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ការរៀបចំប្លង់** | គំរោងនឹងលិចលង់ផ្ទៃដី ៣០៥,៧៤ គ.ម² នៅក្នុងឃុំចំនួនបួន (ភ្លុក ស្រែគរ តាឡាត់ និង ក្បាលរមាស), ផ្លូវជាតិលេខ ៧៨ ប្រវែង ៧គ.ម និង ស្ពានស្រែពក ។ ដីព្រៃឈើរាប់ពាន់ហិកតា នឹង ត្រូវខូចខាតនៅក្នុងតំបន់តាំងទីលំនៅសារជាថ្មី។<br>គំរោងនឹងប៉ះពាល់ទៅលើដីសម្បទានចំនួន៥កន្លែង និងតំបន់ព្រៃសម្បទានមួយកន្លែងផងដែរ ។ | | | ✓ | - ការរៀបចំប្លង់គំរោងគួររចនាធ្វើយ៉ាងណា ដើម្បីបន្ថយផ្ទៃលិចលង់ក្នុងគោលបំណងកាត់បន្ថយការបំផ្លាញព្រៃឈើ ដីកសិកម្ម ផ្ទះសម្បែង ដី និង ព្រៃសម្បទាន។<br>- ការសាងសង់ផ្លូវវាង និង ស្ពានទាមទារអោយមានជាសំណងសំរាប់កំណាត់ផ្លូវនេះ និងស្ពានដែលបាត់បង់ដោយគំរោង។<br>- ការជ្រើសបន្ទាត់ផ្លូវចេញចូល ផ្លូវវាងផ្លូវជាតិលេខ ៧៨ និង តំបន់តាំងទីលំនៅសារជាថ្មី នឹងមានទីតាំងនៅក្នុងតំបន់ ដែលមិនមានផលប៉ះពាល់អាក្រក់ដល់ធនធានធម្មជាតិ និង សង្គមនៅក្នុងតំបន់។ | DE/PO, និង GDE | គ្មាន (DE/PO ជាអ្នកទទួលខុស ត្រូវ) |
| | | | | | - ក្រុមហ៊ុនត្រូវទទួលខុសត្រូវរាល់ការចំណាយសំរាប់សងនូវ សំណង់ផ្លូវ ស្ពាន និង តំបន់តាំងទីលំនៅសារជាថ្មី ហើយ គុណភាពរបស់ផ្លូវ និងស្ពាន គួរមានភាពប្រហាក់ប្រហែល ឬ ប្រសើរជាង របស់ដែលមានស្រាប់។ | DE/PO, DPWT, និង IRC | ម្ចាស់គំរោងជាអ្នកទទួលខុសត្រូវ ហើយតំលៃនឹងមានរួមបញ្ចូលនៅក្នុងតំលៃវិនិយោគ |
| **ទំនប់** | មានផលប៉ះពាល់ខ្ពស់ទៅលើចលនាត្រី/ការផ្លាស់ទី ឡើងចុះតាមទន្លេសេសាន និងទន្លេ ស្រែពក។ | | | ✓ | - ផ្តល់មធ្យោបាយផ្សេងៗសំរាប់ការសំរួលដល់បំលាស់ទីត្រី នឹងត្រូវរៀបចំដាក់ក្នុងការរចនាប្លង់គំរោង បើអាចធ្វើបាន ដូចជា ជណ្តើរត្រី និងប្រឡាយផ្លូវត្រី។ | DE/PO, រដ្ឋបាលជលផល | ថវិកាសាងសង់ និង ថវិកាសំណងត្រូវរួមបញ្ចូល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ទំនប់កាត់ទន្លេសេសាន នឹងមានផលប៉ះពាល់ មិនត្រឹមតែទៅលើផលផលក្នុងតំបន់ប៉ុណ្ណោះ ទេ ថែមទាំងប៉ះពាល់ផងដែរទៅលើ ផលផល នៅខ្សែទឹកក្រោមរបស់ទន្លេមេគង្គ និងដីសណ្ត ទន្លេមេគង្គ ព្រមទាំងបឹងទន្លេសាប ។ | | | | - សំណងដល់សហគមន៍ ដែលរស់នៅតាមដងទន្លេ សេសាន និង ទន្លេស្រែពក សំរាប់ការបាត់បង់ត្រី ធម្មជាតិ នឹងត្រូវផ្តល់អោយជាកម្មវិធីសំរាប់ទ្រទ្រង់ ដល់ជីវភាពរបស់ពួកគេ ដូចដែលពុំទាន់មានគំរោង វារីអគ្គិសនីនេះ ។<br>- ផ្តល់ការបណ្តុបណ្តាលផ្នែកកសិកម្មដូចជា ការចិញ្ចឹម សត្វ ការដាំដុះស្រូវ បន្លែ និងដំណាំផ្សេងៗទៀត ។ | | ក្នុងតំលៃគំរោង វិនិយោគ |
| **ការសាងសង់ផ្លូវ ចូល** | ផលប៉ះពាល់ទៅលើធនធានធម្មជាតិបង្កដោយ សកម្មភាពសាងសង់ដូចជាការកាប់ព្រៃសំរាប់ ធ្វើផ្លូវចូលទៅកាន់តំបន់គំរោង ការដ្ឋានយក ថ្មដី សំលេង រំញ័រ ការផ្គត់ផ្គង់ទឹក គុណភាព ទឹក និង ប្រព័ន្ធរំដោះទឹកចេញជាដើម ។ | ✓ | | | - ក្រុមហ៊ុននឹងត្រូវជ្រើសរើសផ្លូវចេញចូលសមស្រប ហើយ រៀបចំប្លង់ដើម្បីជៀសវាង/ កាត់បន្ថយការខូច ខាត ឬគ្រោះ ថ្នាក់ដល់ធនធានធម្មជាតិ ដូចជាព្រៃឈើ សត្វព្រៃ វារីសត្វ និង វារី រុក្ខជាតិ និងដើម្បីជៀសវាង គ្រោះថ្នាក់មួយចំនួន ដល់ធនធានសង្គមនៅក្នុងតំបន់ ផ្លូវចូលត្រូវតែតភ្ជាប់ ដោយផ្ទាល់ជាមួយ ផ្លូវជាតិលេខ ៧៨ ហើយមិនកាត់តាមភូមិណាមួយទេ ។ | DE/PO, DPWT | ថវិកាសំណង និង ថវិកាដំណើរការ ត្រូវបានបញ្ចូលក្នុង តំលៃគំរោង វិនិយោគ |
| **ជម្លោះដីធ្លី** | អាងស្តុកទឹកដែលបានស្នើឡើងរបស់រោងចក្រ វារីអគ្គិសនីសេសានក្រោម២ នឹងលិចលង់ដី សម្បទាន និងព្រៃសម្បទានមួយចំនួននៅក្នុង តំបន់ដែលមានអជ្ញាប័ណ្ណ និងកំពុងដំណើរការ រួចហើយ ។ ឈ្មោះ ដី និងព្រៃសម្បទានមានៈ | | ✓ | | ក្រុមហ៊ុនប្រតិបត្តិគំរោងរួមជាមួយ MIME នឹងត្រូវសហ ការជាមួយម្ចាស់និងស្ថាប័នទទួលខុសត្រូវលើដីសម្បទាន និង ព្រៃសម្បទានទាំងនោះ ដើម្បីដោះស្រាយជម្លោះដីធ្លី មុនការ ចាប់ផ្តើមគំរោងសាងសង់ ។ | DE/PO, MAFF, MLMUPC, និង អាជ្ញាធរមូលដ្ឋាន | គ្មានតំលៃសំរាប់ដី ប៉ុន្តែមានតំលៃ សំណងសំរាប់ ដំណាំ និង ផលិត ផល ។ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | - ភាពីមិច Phea Phimex<br>- ក្រុមហ៊ុន Green Land Company<br>- ស៊ីវ ហ្គិចកសិ-ឧស្សាហកម្ម Siv Geach Agro-Industrial<br>- ក្រុមហ៊ុន Phumady Investment Group<br>- ក្រុមហ៊ុន Sopheak Nika Investment Agro-Industrial<br>-ក្រុមហ៊ុន Sal Sophear Trade | | | | | | តំលៃសំណងមានបញ្ចូលនៅក្នុងតំលៃគំរោងវិនិយោគ ។ |
| **ការផ្លាស់ប្តូរទីលំនៅសារជាថ្មី** | ជាមួយ FSL ៧៥ ម និង ទីតាំងទំនប់ទី ១ គំរោង នឹងត្រូវផ្លាស់ទីលំនៅប្រជាជនចំនួន ១០៥៩ គ្រួសារ ដែលក្នុងនោះមាន ៣៣២ គ្រួសារក្នុងឃុំស្រែគរ ៤៥៣ គ្រួសារក្នុងឃុំក្បាលរមាស ២៦៧ គ្រួសារនៅក្នុងឃុំតាឡាត់ និង ៧គ្រួសារនៅក្នុងឃុំភ្លុក ។ ជាលទ្ធផលគេនឹងត្រូវផ្លាស់ទីលំនៅលើប្រជាជនប្រហែល ៥០០០ នាក់ ។ | | | ✓ | - ការផ្លាស់ប្តូរលំនៅដ្ឋានចាំបាច់ត្រូវមានទីតាំងសមស្រប ហើយមានទំហំសមរម្យសំរាប់គ្រួសារ ឬប្រជាជនដែលរងផលប៉ះពាល់ អោយបានសមមូល ឬ ប្រសើរជាងលក្ខខណ្ឌរស់នៅ ចំពោះអ្វីដែលពួកគេមាននៅពេលបច្ចុប្បន្ន ។<br>- តំបន់តាំងទីលំនៅសារជាថ្មីគួរជ្រើសរើសនៅកន្លែងដែលមិនមានផលប៉ះពាល់អាក្រក់លើធនធានធម្មជាតិ និង សង្គម ។<br>- សកម្មភាពផ្លាស់ទីលំនៅគួរធ្វើឡើងជាមួយការពិភាក្សាដោយសន្តិវិធីជាមួយប្រជាជនដែលរងផលប៉ះពាល់ ការវាស់វែងត្រឹមត្រូវពីទ្រព្យសម្បត្តិដែលប៉ះពាល់ និង | DE/PO, PECC-1, IRC/MEF, MLMUPC, និង អាជ្ញាធរមូលដ្ឋាន | តំលៃសំណងមានបញ្ចូលនៅក្នុងតំលៃគំរោងវិនិយោគ ។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | សំណងសមស្របដោយ អនុលោមតាមគោលនយោបាយសំណង និងតាមតំលៃជាក់ស្តែងនៅក្នុងទីផ្សារមូលដ្ឋាន ។<br>- ផែនការសកម្មភាពផ្លាស់ប្តូរទីលំនៅត្រូវទាមទារអោយធ្វើ ត្រឹមត្រូវ ហើយប្រសិទ្ធិភាពនៃកាលបរិច្ឆេទសំណងគួរព្រមព្រៀងគ្នាមុនការចាប់ផ្តើមសកម្មភាពសាងសង់ ។ ជាងនេះទៀត សំណង និង សកម្មភាពផ្លាស់ទីលំនៅត្រូវអនុវត្តអោយបានពិតប្រាកដ ដូចរៀបរាប់ក្នុងរបាយការណ៍ផ្លាស់ទីលំនៅ ( របាយការណ៍ដោយឡែកដែលរៀបចំដោយក្រុម សិក្សារបស់ PECC-1) ។ | | |
| ***B. ដំណាក់កាលសាងសង់*** | | | | | | | |
| **ផលប៉ះពាល់លើរបបជលសាស្ត្រ** | ការសាងសង់ទំនប់ និងការសាងសង់/ការស្តារឡើងវិញផ្លូវចូលទៅតំបន់គំរោងនឹងបណ្តាលអោយមានការកកស្ទះនៃប្រព័ន្ធរំដោះទឹកដោយធម្មជាតិ និង ផ្លាស់ប្តូរធារទឹកទន្លេនៅក្នុងតំបន់ និងនៅខ្សែទឹកខាងក្រោមរបស់ទីតាំងគំរោង ។ | ✓ | | | - សំណង់ប្រឡាយបង្វែរនៅទីតាំងទំនប់នឹងត្រូវផ្តល់ជាមួយ នឹងកាប៉ាស៊ីតេគ្រប់គ្រាន់ដើម្បីបញ្ចេញទឹកទៅខ្សែទឹកខាងក្រោមជៀសវាងការផ្លាស់ប្តូរធារទឹកធំផេងនៅក្នុងទន្លេ ។<br>- ផ្តល់ប្រព័ន្ធរំដោះទឹកតាមផ្លូវចូលទៅទីតាំងគំរោង ។ | CE/PO និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ ។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ផលប៉ះពាល់លើគុណភាពទឹក | គុណភាពទឹកនៅខាងក្រោមទីតាំងទំនប់ក្នុងទន្លេសេសាននឹងត្រូវកាត់បន្ថយនៅដំណាក់កាលសាងសង់ ដោយសារការកាប់ព្រៃឈើ ការលើកដី ការចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ឬ នៅកន្លែងទំនេរជិតទន្លេ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិល និងសារធាតុពុលផ្សេង ទៀតពីគ្រឿងចក្រ / រថយន្តធំៗ សំរាប់សំណង់ និងការងារសាងសង់។ | | ✓ | | - ការកាប់ព្រៃ និង ការលើកដីគួរធ្វើនៅក្នុងរដូវប្រាំង។<br>- វិធានការត្រួតពិនិត្យសំណឹក និង កករនឹងត្រូវដាក់ចូល ដូចជា អាងស្ទាក់ទប់ និងក្រណាត់/ប្លាស្ទិកខៀវ ដែលមានក្រឡាតូចល្អិត នឹងត្រូវដាក់ប្រើនៅការដ្ឋានសាងសង់ ដើម្បីជៀសវាងកំទេចកំណ កករដីដែលហូរពីរតំបន់គំរោង នៅក្នុងរដូវវស្សា។<br>- ផ្តល់ទីកន្លែងគ្រប់គ្រងកាកសំណល់អោយបានគ្រប់គ្រាន់ដោយ រាប់បញ្ចូលទាំងបង្គន់អនាម័យនៅក្នុងកការដ្ឋានសាងសង់ និង ជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ។ | CE/PO និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ។ |
| | | | | | - ការត្រួតពិនិត្យគុណភាពទឹកនៅផ្នែកខ្សែទឹកខាងក្រោម និងខ្សែទឹកខាងលើនៃតំបន់គំរោង ត្រូវធ្វើអោយបានទៀងទាត់ ដើម្បីធានាបានពីគុណភាពទឹកក្នុងពេលសាងសង់មិនធ្វើអោយមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រភពទឹក ។ | CE/PO និង DPC | ១២០០ ដុល្លា ក្នុង១ឆ្នាំ រយះពេល៥ឆ្នាំ |
| ផលប៉ះពាល់លើខ្យល់បរិយាកាស | ការបំភាយខ្យល់ក្រខ្វក់ ធូលី សំលេង និង រំញ័រចេញពីការកាប់/ការដុត ព្រៃឈើ/សារពើរុក្ខជាតិ នៅក្នុងតំបន់សំណង់ និង នៅក្នុងផ្លែអាង គ្រឿងចក្រសំណង់ ការបំផ្ទុះថ្ម និងការដឹកជញ្ជូនសំភារៈសំណង់ នឹងប៉ះពាល់ដល់គុណភាពខ្យល់បរិយាកាស ។ | ✓ | | | - ក្រុមហ៊ុននឹងស្នើ សុំអោយមានបង្កើតគណៈកម្មការមួយ របស់រដ្ឋបាលព្រៃឈើដើម្បីធ្វើការងារដោះស្រាយលើធនធានព្រៃឈើនៅក្នុងទីតាំងគំរោង (អាងស្តុកទំនប់ អាគារផលិតថាមពល និងតំបន់សំរាប់ការតាំងទីលំនៅសារជាថ្មី) ។<br>- ក្រុមហ៊ុននឹងសហការជាមួយរដ្ឋបាលព្រៃឈើដើម្បី | CE/PO និង អ្នកម៉ៅការ | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ភ្លើងឆេះព្រៃបណ្តាលពីការធ្វេសប្រហែសរបស់បុគ្គលិកគំរោង ព្រានព្រៃ និង ការរានដីដើម្បីកាន់កាប់ ឬ ដើម្បីដាំដុះនៅក្នុងតំបន់នឹងបំពុលបរិយាកាសនៅក្នុងតំបន់គំរោង ក៏ដូចជាក្នុងតំបន់ទាំងមូលផងដែរ។ | | | | ប្រមូល និង កែលំអឈើសំរាប់គោលបំណងប្រើប្រាស់មួយចំនួន ឬលក់ ទៅទីផ្សារជាជាងដុតចោលដើម្បីកាត់បន្ថយការបំពុលខ្យល់។<br>- ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងចក្រសំណង់ដែលមានគុណភាពល្អ និងមានការបំពុលខ្យល់តិចតាមដែលអាចធ្វើបាន។<br>- ក្រុមហ៊ុននឹងប្រើប្រាស់សំភារៈបំផ្ទុះ និងបច្ចេកទេសសមរម្យ ដើម្បីកុំអោយមានការបំពុលខ្ពស់សាយភាយចូល ទៅក្នុងខ្យល់។ | | |
| ភូគព្ភសាស្ត្រ/ការ សិក្សាពីរញ្ជួយដី | មានស្នាមប្រេះស្រុតភូគព្ភសាស្ត្របួនកន្លែងនៅក្នុង និងនៅជុំវិញតំបន់គំរោង។ មានរញ្ជួយដីម្តងកើត ឡើងនៅក្បែរតំបន់គំរោងក្នុងឆ្នាំ ១៩៧៨ ដែល កំរិតទំហំ $M_s$=៥.២ រង្វាស់ Richter ។ ដូចនេះការ អនុវត្តន៍រោងចក្រវារីអគ្គិសនីសេសានក្រោមទី២ ស្ថិតនៅក្នុងភាពប្រថុយប្រថានពីសកម្មភាពរញ្ជួយផែនដី ដោយសារសំណង់ទំនប់ និង អាងស្តុកមានកាប៉ាស៊ីតេផ្ទុករាប់លានម៉ែត្រគ្រីគុណ។ | | ✓ | | - ទំនប់មេរបស់រោងចក្រវារីអគ្គិសនីទន្លេសេសានក្រោមទី២ នឹងត្រូវសង់លើកន្លែង ដែលមានលក្ខណៈភូគព្ភសាស្ត្រសមរម្យដែលជាជំរើសទីតាំងទំនប់ ១។<br>- វិចនាសម្ព័ន្ធរូបសាស្ត្រទាំងអស់រាប់បញ្ចូលទាំងទំនប់មេនឹងត្រូវរៀបចំប្លង់ឡើងដោយមានការការពារខ្ពស់ពីសកម្មភាពរញ្ជួយដីនៅក្នុងតំបន់។ | DE/PO | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ហេតុប៉ះពាល់ទៅលើព្រៃឈើ និង ជីវកសត្វព្រៃ | នៅកំរិត FSL ៧៥ ម គំរោងនឹងត្រូវបំផ្លាញព្រៃស្លួតរដូវប្រាំង ព្រៃពាក់កណ្តាលស្រោង ព្រៃស្រោង និង ព្រៃផ្សេងទៀត និងវាលស្មៅ សរុបជាង ៣ម៉ឺនហិកតា។ ព្រៃជាច្រើនហិកតានឹងត្រូវខូចខាត/បាត់បង់ដោយការស្ថាបនារបស់គំរោងរាបបញ្ចូលទាំងផ្លូវចូល ផ្លូវវាង ទៅកាន់ផ្លូវ លេខ ៧៨ ផងដែរ។ ការបាត់បង់ជីវកសត្វព្រៃនៅ ក្នុងតំបន់អាងស្តុក តាមបណ្តោយផ្លូវចូល ផ្លូវវាង និងកន្លែងសាងសង់ផ្សេងទៀតរបស់គំរោង នឹងត្រូវកើតឡើង។ តំបន់តាំងទីលំនៅសារជាថ្មីដែល ស្មើឡើងនឹងប៉ះពាល់ផងដែរដល់ព្រៃឈើ និង ជីវកសត្វព្រៃ ដែលមានផ្ទៃសរុបច្រើនជាងពី ៣ ទៅ ៤ពាន់ហិកតា ។ | | | ✓ | - ការកាប់ព្រៃឈើនឹងត្រូវធ្វើឡើងតែនៅក្នុងផ្ទៃដីរបស់តំបន់គំរោង នៅកន្លែងដែលត្រូវការសំរាប់សកម្មភាពសាងសង់តែប៉ុណ្ណោះ ។<br>- ហាមឃាត់ដាច់ខាតកម្មករសំណង់ពីការទន្ទ្រានចូលទៅក្នុងព្រៃសំរាប់ការបរបាញ់ ឬការកាប់ឆ្ការព្រៃឈើក្រៅពី តំបន់គំរោង ទោះក្នុងគោលបំណងណាក៏ដោយ ។ | CE/PO and អ្នកម៉ៅការ | គ្មាន |
| | | | | | - ក្រុមហ៊ុននឹងធ្វើការផ្តល់វិភាគទានផងដែរ ដើម្បីពង្រឹងកម្មវិធីអភិរក្សព្រៃឈើ និង ជីវកសត្វព្រៃ នៅក្នុងតំបន់ដោយរាប់បញ្ចូលការធ្វើសហប្រតិបត្តិការ និងការផ្តល់ថវិកាដល់ FA និង ភ្នាក់ងារអភិរក្សដែលមានទំនាក់ទំនងផ្សេងទៀត នៅក្នុង និងនៅជុំវិញតំបន់គំរោង។ ស្ថានីយ៍បណ្តុះកូនឈើមួយនឹងត្រូវរៀបចំផ្តល់នៅជាប់តំបន់អាងស្តុកទឹក ។ | CE/PO និង MoE | ការគាំទ្រកម្មវិធីអភិរក្សព្រៃឈើនិងជីវកសត្វព្រៃនឹងមានដាក់នៅក្នុងមូលនិធិបរិស្ថានប្រចាំឆ្នាំដែលម្ចាស់គំរោងនឹងបង់ជូនស្ថាប័នទទួលខុសត្រូវ (*) |
| ហេតុប៉ះពាល់ទៅលើសត្វព្រៃ | សកម្មភាពអភិវឌ្ឍន៍ និង សកម្មភាពជាច្រើនរបស់មនុស្សកំពុងមានសំពាធដល់ជីវកសត្វព្រៃ និងសត្វព្រៃរួចជាស្រេចទៅហើយ ឧទាហរណ៏:-កិច្ចប្រតិបត្តិការរបស់ដសម្បទាន | | ✓ | | - ការកាប់ព្រៃឈើនឹងត្រូវធ្វើឡើងត្រឹមតែនៅក្នុងតំបន់ដែលត្រូវការប៉ុណ្ណោះសំរាប់សកម្មភាពសាងសង់។<br>- ការបំផ្ទុះថ្ម និងប្រតិបត្តិការរបស់គ្រឿងចក្រសំណង់នឹងធ្វើឡើងដោយមានការកំណត់សំលេង និង រំញ័រ | CE/PO និង អ្នកម៉ៅការ | គ្មាន |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និងព្រៃសម្បទាន និង ការបរបាញ់សត្វ ដូចនេះ ផលប៉ះពាល់ដល់សត្វព្រៃ ដែលបណ្តាលពីការសាងសង់គំរោង នឹងកើតមានជាមធ្យមដោយសារការរំខានធ្លាប់មាន រួចជាស្រេចហើយ ប៉ុន្តែការបាត់បង់ទីជំរកនៅក្នុងអាងស្តុក និង តំបន់តាំងទីលំនៅសារជាថ្មី សំលេងរំខាន និង រំញ័រពីម៉ាស៊ីនសាងសង់ ការបំផ្ទុះយកថ្ម ការកាប់ព្រៃឈើ និង ការទន្ទ្រានចូលទីជំរកសត្វព្រៃ<br>ដោយកម្មករសាងសង់នឹងបណ្តាលអោយមានផលប៉ះពាល់បន្ថែមទៀតទៅលើធនធានទាំងនោះ ។ | | | | ហើយធ្វើតែនៅពេលថ្ងៃប៉ុណ្ណោះ សំរាប់ដំណាក់កាលសាងសង់ទាំងមូល ។<br>- ហាមឃាត់ដាច់ខាតដល់កម្មករសំណង់មិនអោយចូលទៅក្នុងព្រៃដើម្បីបរបាញ់ ឬ កាប់ព្រៃឈើ ។ | | |
| **ហេតុប៉ះពាល់ទៅលើវារីជីវៈ និង ជលផល** | កករទឹក និង កំទេចកំទី/កំណកល្បាប់ពីសកម្មភាពសាងសង់នឹងធ្វើអោយខូចខាតដល់ជីវិតក្នុងទឹកនៅបាតទន្លេ ។ គឺរិតរលាយអុកស៊ីសែនទាប បរិមាណខ្ពស់នៃប្រេង និង ខ្លាញ់ដែលមានសក្តានុពល និង ប៉ារ៉ាម៉ែត្រពុលនៅក្នុងទឹកនឹងប៉ះពាល់ដល់សត្វក្នុងទឹក និង ត្រីដោយសារវាមិនអាចលូតលាស់បន្តពូជ និង មានជីវិតរស់ | | | ✓ | - វិធានការត្រួតពិនិត្យកករ និង សំណឹកសមស្រប ដូចជាស្រះសំរាប់ស្ទាក់ចាប់ និង សំណាញ់ប្លាស្ទិក/ក្រណាត់ពណ៌ខៀវដែលមានក្រឡាតូចៗ នឹងត្រូវដាក់អោយចំកន្លែងនៃការដ្ឋានគំរោង ដើម្បីជៀសវាងការរងកករពីការហូរចាក់ពីតំបន់សាងសង់ជាពិសេសនៅរដូវភ្លៀង ។<br>- ក្រុមហ៊ុនសាងសង់នឹងអប់រំដល់កម្មករកុំអោយបោះកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់នៅមធ្យោបាយគ្រប់គ្រងកាកសំណល់គ្រប់គ្រាន់ដោយរាប់បញ្ចូលទាំង | CE និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ ។ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នៅបាន។ នៅពេលខ្លះបុគ្គលិក និង កម្មករគំរោងអាចធ្វើការនេសាទ ខុសច្បាប់នៅក្នុងទន្លេ ហើយបណ្តាលអោយប៉ះពាល់ទៅលើផលផលនៅក្នុងតំបន់នេះផងដែរ។ | | | | បង្គន់អនាម័យនៅក្នុងកន្លែងសាងសង់ និង ជំរុំស្នាក់នៅរបស់ បុគ្គលិក/កម្មករ។<br>- ក្រុមហ៊ុននឹងធ្វើអោយប្រាកដថា កាកសំណល់ទាំងអស់ដែលកើតចេញពីមនុស្ស និង សកម្មភាពសាងសង់ទាំងអស់ត្រូវបានប្រមូលទុកដាក់ ដឹកជញ្ជូន និង បោះចោលដោយអនុលោមទៅតាមការណែនាំ/បទដ្ឋានរបស់ប្រទេសកម្ពុជាពីការគ្រប់គ្រងកាកសំណល់។<br>- សកម្មភាពនេសាទខុសច្បាប់ពីបុគ្គលិក និង កម្មករគំរោងគួរហាមឃាត់ជាដាច់ខាត។ | | |
| | | | | | - ផ្តល់មធ្យោបាយ សមស្របដើម្បីអោយត្រី និងវារីសត្វដទៃទៀតមានវត្តមានឡើង វិញក្នុងតំបន់គំរោង ដោយបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងភ្ញាស់ពូជត្រី ដើម្បីជួយថែរក្សាអោយ មានតុល្យភាពត្រីនៅខាងលើ និងខាងក្រោមខ្សែទឹកនៃទីតាំងគំរោង។ | OE/PO, រដ្ឋបាលជលផល/ក្រសួងកសិកម្ម | ០.៤ លានដុល្លាអាមេរិកសំរាប់ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនិងភ្ញាស់កូនត្រី |
| **ហេតុប៉ះពាល់ទៅលើការផ្គត់ផ្គង់ទឹក** | គំរោងនឹងប៉ះពាល់ទៅលើការផ្គត់ផ្គង់ទឹករបស់សហគមន៍នៅខ្សែទឹកខាងក្រោមរួមមានការផ្គត់ ផ្គង់ទឹកនៅសហគមន៍ភ្លុក និង ការផ្គត់ផ្គង់ទឹកនៅ ទីរួមខេត្តស្ទឹងត្រែង អំឡុងពេលនៃសកម្មភាពសាងសង់ ដោយសារការធ្លាក់ | | ✓ | | - វិធានការត្រួតពិនិត្យកករ និង សំណើសមស្រប ដូចជាស្រះសំរាប់ស្ទាក់ចាប់ និង សំណាញ់ប្លាស្ទិក/ក្រណាត់ពណិខ្សែវដែលមានក្រឡាតូចៗ នឹងត្រូវដាក់អោយចំកន្លែង នៃការដ្ឋានគំរោង ដើម្បីជៀសវាងការរងកករពីការហូរចោក់ ពីតំបន់សាងសង់ជាពិសេសនៅរដូវភ្លៀង។ | CE និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ។ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ចុះគុណភាពទឹកនៅទន្លេសេសាន ។ តំលៃធ្វើប្រព្រឹត្តិកម្មសំអាតទឹក របស់រដ្ឋាករទឹកខេត្តនឹងត្រូវកើនឡើង ។ | | | | - ផ្តល់ការគប់គ្រងកាកសំណល់អោយបានគ្រប់គ្រាន់ ដោយរាប់បញ្ចូលទាំងបង្គន់អនាម័យនៅការដ្ឋានសាងសង់ និង ជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ ។<br>- ម្ចាស់គំរោងនឹងផ្តល់ការបង់តំលៃសំណងដល់អ្នកប្រើប្រាស់ទឹកនៅខ្សែទឹកក្រោមប្រសិនបើគុណភាពទឹកខូចខាតធ្ងន់ធ្ងរដោយសកម្មភាពគំរោង ។ | | |
| **ហេតុប៉ះពាល់ទៅលើផ្លូវថ្នល់** | ក្នុងដំណាក់កាលសាងសង់គំរោងនឹងប៉ះពាល់ទៅ លើផ្លូវថ្នល់ និង ស្ពានដែលមានស្រាប់នៅក្នុងតំបន់ ជាពិសេសផ្លូវជាតិលេខ ៧៨ ស្ពានស្រែពក និង ស្ពាននៅតាមដងផ្លូវនេះ ។ | ✓ | | | - នឹងធ្វើការកែលំអ ជាចាំបាច់នូវផ្លូវ និង ស្ពានមានស្រាប់ដែលនឹងប្រើប្រាស់សំរាប់គំរោង ។<br>- ធ្វើទាំអោយបានញឹកញាប់នូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និង ផ្លូវចេញចូលដែលនឹងត្រូវប្រើប្រាស់សំរាប់គំរោង ដើម្បីធានាបាននូវដំណើរការល្អក្នុងកំឡុងពេលសាងសង់ ។<br>- កែលំអកំណាត់ផ្លូវជាតិលេខ ៧៨ ដែលប្រើប្រាស់សំរាប់គំរោង ប្រសិនបើវាមិនទាន់បានកែលំអនៅឡើយមុនការចាប់ផ្តើមគំរោងសាងសង់ ។ | CE/PO, DPWT និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ ។ |
| **ហេតុប៉ះពាល់ទៅលើនាវាចរណ៍** | គំរោងនឹងរំខានដល់ការធ្វើនាវាចរណ៍របស់កាណូតតូចដែលប្រជាជនក្នុងមូលដ្ឋានតែងប្រើប្រាស់ជាញឹកញាប់សំរាប់ដឹកជញ្ជូនពីភូមិមួយទៅភូមិមួយ និងជូនកាលទៅកាន់ទីរួម | ✓ | | | - ផ្តល់ផ្លូវនាវាចរណ៍សំរាប់កាណូតតូចៗតាមប្រឡាយបង្វែរ ដែលបានស្នើឡើងដោយ គំរោងក្នុងដំណាក់កាលសាងសង់ ។<br>- បញ្ជាក់ប្រាប់ដល់អ្នកបើកបរ/អ្នកភូមិពីផ្លូវនាវាចរណ៍ | CE/PO, DPWT និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ ។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ខេត្តស្ទឹងត្រែង ។ | | | | (កាត់តាមប្រឡាយបង្វែរ) នៅតំបន់ផ្លូវកាត់ទីតាំងទំនប់ កំឡុងពេលដំណាក់កាលសាងសង់ ។ ស្លាកសញ្ញាផ្លូវនាវាចរណ៍នៅកន្លែងចូល និងចេញតាមប្រឡាយបង្វែរនឹងមានផ្តល់អោយដោយគំរោង ។ | | |
| ហេតុប៉ះពាល់ទៅលើដីប្រើប្រាស់ | គំរោងនឹងធ្វើអោយខូចខាត និងផ្លាស់ប្តូរ ដីប្រើប្រាស់នៅក្នុងតំបន់ដោយសារសំណង់របស់គំរោង ដូចជាការសាងសង់ទំនប់ផ្ទៃអាងស្តុកទឹក ការកាប់ឆ្ការព្រៃ ការសាងសង់នៅតំបន់តាំងទីលំនៅសារជាថ្មី ផ្លូវចេញចូល ផ្លូវវាង និងសមាសធាតុ សំណង់ផ្សេងៗរបស់គំរោង ។ | | ✓ | | - ផ្ទៃអាងស្តុកទឹកនឹងត្រូវបន្ថយអោយបានអប្បបរិមាតាមដែល អាចធ្វើបាន ដោយកំពស់ទឹកលិចមិនលើសពី ៧៥ម (ធៀបទៅនឹងទឹកសមុទ្រ) ។<br>- កំណត់ទំហំតំបន់តាំងទីលំនៅដោយផ្អែកតាមតំរូវការជាក់ស្តែង ហើយការរានដីបន្ថែមដែលនៅក្បែរតំបន់តាំងទីលំនៅត្រូវហាមឃាត់ជាដាច់ខាត ។ | CE/PO, DPWT, IFC/MEF, និង អ្នកម៉ៅការ | គ្មាន |
| ហេតុប៉ះពាល់ទៅលើការអភិវឌ្ឍន៍កសិកម្ម | គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ នឹងប៉ះពាល់ដល់ដីកសិកម្ម ១២៩០ ហ.ត ត្រូវជា ២៤.៧% នៃដីកសិកម្មសរុបក្នុងស្រុកសេសានទាំងមូល ។ គំរោងនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការ អភិវឌ្ឍន៍កសិកម្មក្នុងកំឡុងពេលសាងសង់ និង កំឡុងពេលផ្លាស់ប្តូរទីលំនៅរបស់គ្រួសារ/ប្រជាជនដែលរងផលប៉ះពាល់ ។ | | ✓ | | - អាងស្តុកនឹងមានទឹកពេញបន្ទាប់ពីការប្រមូលផលិតផលកសិកម្មនៅក្នុងតំបន់អាង ។<br>- ក្រុមហ៊ុននឹងរៀបចំដីកសិកម្មនៅក្នុងតំបន់តាំងទីលំនៅសារជាថ្មី ទាន់ពេលវេលាសំរាប់គ្រួសារ/ប្រជាជន ដែលទទួលរងផលប៉ះពាល់ ដើម្បីបន្តការដាំដុះស្រូវ នៅរដូវបន្ទាប់ក្រោយពីបញ្ចប់សកម្មភាពកសិកម្មនៅក្នុងកន្លែងដើម ។ | CE/PO, DPWT, IFC/MEF, និង អ្នកម៉ៅការ | គ្មាន |



Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| ហេតុប៉ះពាល់ទៅលើវប្បធម៌មូលដ្ឋាន | គំរោងអាចមានជម្លោះវប្បធម៌ ប្រសិនបើគំរោងជ្រើសរើសបុគ្គលិកពីខាងក្រៅ ដែលមានវប្បធម៌ផ្សេងគ្នាទៅធ្វើការអោយការសាងសង់គំរោង។ សកម្មភាពមួយចំនួនពីបុគ្គលិកគំរោងដូចជាសំលេងរំខាន ការទន្រ្ទានចូលកន្លែង/ព្រៃសក្ការៈបូជា និង ភាពមិនស្មោះត្រង់/ប្រឆាំងនឹងជំនឿ/វប្បធម៌មូលដ្ឋាន អាចបង្កជាផលប៉ះពាល់ទៅលើវប្បធម៌របស់ប្រជាជនមូលដ្ឋាន និង ក្រុមជនជាតិនៅក្នុងតំបន់គំរោង។ | ✓ | | | - អប់រំកម្មករ និង បុគ្គលិកគំរោងអោយគោរព និង ស្តាប់តាមវប្បធម៌របស់ប្រជាជនមូលដ្ឋានក៏ដូចជាបទបញ្ញា និង ច្បាប់របស់រាជរដ្ឋាភិបាលពីជំនឿសាសនា និង វិន័យផ្សេងទៀតដែលពាក់ព័ន្ធនឹងវប្បធម៌ ប្រពៃណី និង អរិយធម៌។<br>- ដាក់វិន័យតឹងតែងដល់កម្មករ ឬ បុគ្គលិកគំរោងណាដែល ធ្វើសកម្មភាពខុសច្បាប់ជាមួយប្រជាជនមូលដ្ឋាន ឬ ពិន័យតាមច្បាប់ចំពោះអ្នកដែលមិនគោរព និង ស្តាប់តាមវប្បធម៌ជនជាតិនៅក្នុងតំបន់គំរោង។ | CE/PO, និង អ្នកម៉ៅការ | គ្មាន |
| ហេតុប៉ះពាល់ទៅលើសុខភាពសាធារណៈ | ការកាប់បំផ្លាញ ការដុតព្រៃឈើ ការដឹកជញ្ជូន សំភារៈសំណង់បញ្ចេញខ្យល់ក្រខ្វក់ ធូលីសំលេង បំផ្ទុះ និង រំញ័រចេញពី សកម្មភាពគំរោង អាចប៉ះពាល់ដល់សុខភាពកម្មករ និង ប្រជាជននៅក្នុងសហគមន៍ ជាពិសេសសហគមន៍ភ្នុក និងច្រប់។<br><br>ទឹកគ្មានគុណភាពនៅក្នុងទន្លេសេសានបណ្តាលពី សកម្មភាពសាងសង់នឹងប៉ះពាល់ដល់សុខភាពរបស់សហគមន៍ដែលនៅខ្សែទឹកខាង | | ✓ | | - ការងារសាងសង់នឹងត្រូវអនុវត្តធ្វើតាមនូវរាល់បទដ្ឋានសុវត្ថិភាពការងារ។ ឧបករណ៍ និង គ្រឿងប្រើប្រាស់នឹងត្រូវផ្តល់គ្រប់គ្រាន់ ដើម្បីការពារគ្រោះថ្នាក់ណាមួយដល់បុគ្គលិកគំរោងព្រមទាំងប្រជាជនមូលដ្ឋាន។<br>- ផ្តល់មណ្ឌលថែរក្សាសុខភាព ថ្នាំសង្កូវ និង គ្រូពេទ្យ/វេជ្ជបណ្ឌិតសំរាប់ពិនិត្យ និង ព្យាបាលបុគ្គលិកគំរោង និង ប្រជាជនមូលដ្ឋាន ដើម្បីជៀសផុតពីការរាលដាលនៃជំងឺដល់ប្រជាជន។<br>- សហប្រតិបត្តិការល្អជាមួយស្ថាប័នសុខភាពក្នុងស្រុក | CE/PO, ប៉ូលីស និង អ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ក្រោម។ កម្មករ/បុគ្គលិករបស់គមរោងមកពីខាងក្រៅ អាចប៉ះពាល់ដល់សុខភាពរបស់ប្រជាជនមូលដ្ឋានតាមរយៈការចម្លងជំងឺសង្គម ដូចជា HIV/AIDS ជំងឺកាមរោគផ្សេងៗ ។ល។ និង ការប្រើប្រាស់ និង ការធ្វើចរាចរណ៍ថ្នាំញៀន។ | | | | សេសាន ខេត្តស្ទឹងត្រែង និង ថ្នាក់កណ្តាល ដើម្បីការពារ ការឆ្លងជំងឺនៅក្នុង និងនៅជុំវិញតំបន់គំរោង។<br>- សហការជាមួយប៉ូលីស និង អាជ្ញាធរមូលដ្ឋាន ដើម្បីការពារប្រឆាំងនឹងការប្រើប្រាស់ថ្នាំញៀន និង ការធ្វើចរាចរណ៍ថ្នាំញៀននៅក្នុងតំបន់គំរោង។ | | |
| **ការបំផ្ទុះ** | ការបំផ្ទុះថ្មសំរាប់សាងសង់ទំនប់ និងផ្លូវចេញចូល អាចប៉ះពាល់ដល់ប្រជាជន សត្វព្រៃ និងគុណភាពខ្យល់បរិយាកាស ដោយសារការបញ្ចេញ សំលេង រំញ័រ និងការបំពុលខ្យល់។<br>ការបំផ្ទុះអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់អ្នកភូមិ ឬ ជីវិតសត្វព្រៃដែលដើរ/នៅជិតតំបន់បំផ្ទុះ។ | ✓ | | | - ការបំផ្ទុះត្រូវធ្វើនៅក្នុងដែនកំណត់ដែលត្រូវគិតពិចារណាពីតំបន់ដើម្បីជៀសវាងគ្រោះថ្នាក់ខ្ពស់ដល់សត្វព្រៃ និង មនុស្សនៅក្នុងតំបន់។<br>- ផ្សព្វផ្សាយអោយបានគ្រប់គ្រាន់ដល់អាជ្ញាធរ ក៏ដូចជាសហគមន៍ អំពីកាលវិភាគបំផ្ទុះ (កាលបរិច្ឆេទ និង ពេលវេលា) ដើម្បីជៀសផុតពីគ្រោះថ្នាក់ណាមួយ ដល់មនុស្ស និង សត្វ។<br>- ការបំផ្ទុះនឹងត្រូវធ្វើឡើងតែនៅពេលថ្ងៃប៉ុណ្ណោះ។ | CE/PO, និងអ្នកម៉ៅការ | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ។ |
| **ចរាចរ** | ភាពមមាញឹកនៃចរាចរ និង គ្រោះថ្នាក់ចរាចរ អាចកើតឡើងនៅលើផ្លូវជាតិលេខ ៧៨ និង ផ្លូវចេញចូលទៅកាន់តំបន់គំរោងដោយសារការដឹកជញ្ជូនសំភារៈសំណង់។ | ✓ | | | - គំរោងនឹងផ្តល់ស្លាកសញ្ញាចរាចរណ៍អោយបានគ្រប់គ្រាន់ តាមបណ្តោយផ្លូវជាតិលេខ ៧៨ និង ផ្លូវចេញចូលរបស់ គំរោង។<br>- អប់រំអ្នកបើកបររបស់គំរោងដើម្បីកំណត់ល្បឿននៅតំបន់ទីលំនៅ ឬកន្លែងដែលមានប្រជាជនកកកុញ។ | CE/PO, DPWT, និង អ្នកម៉ៅការ | ៣០០០ ដុល្លា ក្នុង១ឆ្នាំ រយៈពេល ៥ឆ្នាំ |



Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| **គ្រាប់មិនទាន់ផ្ទុះ និងធាតុគីមីពុល** | ហានិយភ័យចំពោះគ្រាប់មិនទាន់ផ្ទុះ និង ធាតុគីមីពុល ដែលនៅសល់ពីការប្រើប្រាស់ ដោយកងទ័ពអាកាសសហរដ្ឋអាមេរិកសម័យសង្គ្រាមនៅឥណ្ឌូចិន នឹងអាចកើតឡើងចំពោះកម្មករ និង ប្រជាជនក្នុងតំបន់ក្នុងពេលសាងសង់គំរោង ។ | | ✓ | | - ការដោះមីននឹងត្រូវធ្វើឡើងមុនពេលការសាងសង់ចាប់ផ្តើម ពិសេសនៅកន្លែងសាងសង់នានា កន្លែងតាំងទីលំនៅសារជាថ្មី និង កន្លែងយកដីនិងថ្ម។<br>- ម្ចាស់គំរោងនឹងធ្វើកិច្ចសហការល្អជាមួយភ្នាក់ងារដោះមីន ដើម្បីដោះស្រាយបញ្ហានេះ ។<br>- ដីដែលមានធាតុគីមីពុល នឹងត្រូវធ្វើការសំអាតឡើងវិញ។ | CE/PO, អាជ្ញាធរមូលដ្ឋាន និង ភ្នាក់ងារដោះមីន | មានបញ្ចូលនៅក្នុងតំលៃគំរោង វិនិ យោគ។ |
| ***C.ដំណាក់កាលប្រតិបត្តិ*** | | | | | | | |
| **ហេតុប៉ះពាល់លើរបបជលសាស្ត្រ** | ធារទឹកនៅខ្សែទឹកក្រោមតំបន់គំរោងរបស់ទន្លេ សេសាននឹងត្រូវផ្លាស់ប្តូរដោយសារការប្រតិបត្តិការរបស់គំរោង។ ធារទឹកសរុបដែលរៀបចំបួង ក្នុងគំរោងស្មើសុំគឺ ២០៣៥ ម³/វិនាទី និង ធារទឹកសំរាប់អូសទួប៊ីនមួយ គឺ ៤០៧ ម³/វិនាទី។<br>- ជាមួយនឹងសេនារីយ៉ូ មានទំនប់ពីរនៅលើទន្លេសេសាន គឺ យ៉ាលី (Yali) និង សេសានក្រោមទី២ និងគ្មានទំនប់នៅលើទន្លេស្រែពក: នោះធារទឹកថយចុះប្រហែលជា ១% ធៀបនឹងស្ថានភាព | | ✓ | | - ក្រុមហ៊ុននឹងផ្តល់អោយបានគ្រប់គ្រាន់បរិមាណទឹកទៅខ្សែទឹកក្រោម កំឡុងពេលប្រតិបត្តិដែលអាចធានាបានពីការថែរក្សាប្រព័ន្ធអេកូឡូស៊ីទន្លេមានជីវិត និង ដើម្បីកុំអោយមានផលប៉ះពាល់ជាអវិជ្ជមាន ខ្ពស់ទៅលើប្រជាជន និង វារីសត្វ និង វារីរុក្ខជាតិនៅខ្សែទឹកក្រោមនៃតំបន់គំរោង។ នៅរដូវវស្សាវបញ្ចេញធារទឹកសំរាប់ប្រតិបត្តិការពេញទំហឹង ហើយនៅរដូវប្រាំងបញ្ចេញធារទឹកជាមួយការរក្សាទុកទួប៊ីនមួយ អោយនៅដំណើការជានិរន្តន៍ ដើម្បីធានាបានចំពោះរំហូរបរិស្ថាននៅខ្សែទឹកខាងក្រោមនៃទីតាំងទំនប់មានប្រមាណជា ២០០ម៣/វិនាទី ។ | OE/PO | មានបញ្ចូលនៅក្នុងតំលៃគំរោង វិនិ យោគ។ |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | ដើមនៅឆ្នាំ ២០០០ ។ មានន័យថាមានការប្រែប្រួលរបបទឹកប្រចាំថ្ងៃតិចតួចនៅរដូវប្រាំង ហើយនៅរដូវវស្សាវិញពុំមានបញ្ហាទេ ។<br>- ជាមួយនឹងសេនារីយ៉ូ មានទំនប់ ៦នៅលើទន្លេសេសាន ( យ៉ាលី សេសាន៣ សេសាន៣ក សេសាន៤ សេសាន៤ក សេសានក្រោមទី២) និង ២ទៀតនៅលើទន្លេស្រែពក (ស្រែពក៣ និងស្រែពក៤): នោះធារ ទឹកថយចុះ ប្រហែល ២% ធៀបនឹងស្ថានភាព ដើមនៅឆ្នាំ ២០០០ ។ មានន័យថាមានការប្រែប្រួលរបបទឹកប្រចាំថ្ងៃ នៅរដូវប្រាំង ប៉ុន្តែនៅរដូវវស្សាវិញ ពុំមានបញ្ហាធំដុំទេ ។ | | | | - ជូនព័ត៌មានអោយបានគ្រប់គ្រាន់ពីកាលវិភាគដំណើរការ និង កាលវិភាគបញ្ចេញទឹកដល់សហគមន៍ នៅខ្សែទឹកខាងក្រោម ដើម្បីជៀសផុតពីគ្រោះថ្នាក់ណាមួយដល់ទ្រព្យសម្បត្តិ នៅតាមច្រាំងទន្លេ និង ជីវិតមនុស្ស ក៏ដូចសត្វនានាផងដែរ ។<br>- ម្ចាស់គំរោងនឹងផ្តល់សំណងដល់ប្រជាជនមួយចំនួនដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយធារទឹកពីទំនប់ ។<br>- ការពិនិត្យតាមដានពីវារីសត្វ និង វារីរុក្ខជាតិនៅខ្សែទឹកក្រោមរបស់តំបន់គំរោង នឹងត្រូវអនុវត្តជាបន្តបន្ទាប់នៅក្នុងដំណាក់កាលប្រតិបត្តិការ ។ ប្រសិនបើផលប៉ះពាល់អាក្រក់ត្រូវបានកំណត់ឃើញ ម្ចាស់គំរោងត្រូវចាត់វិធានការចាំបាច់ ជាជំហានៗ ដើម្បីធ្វើអោយប្រសើរឡើងវិញនូវបញ្ហាទាំងនោះ ។ | | |
| **ហេតុប៉ះពាល់លើគុណភាពទឹក** | ក្នុងរយៈពេលប្រតិបត្តិការ ១-៣ ឆ្នាំដំបូង ទឹកនៅក្នុងអាងអាចមានភាពមិនល្អ ដោយសារការស្អុយរលួយនៃព្រៃឈើ ឬ សាពើរុក្ខជាតិ និង សត្វតូចៗដែលជាប់ក្នុងផ្ទៃលិចលង់ | | ✓ | | - កាប់ និង ឆ្ការសំអាតព្រៃ និង សារពើរុក្ខជាតិនៅតំបន់អាងស្តុក មុនពេលបំពេញទឹកក្នុងអាង ដើម្បីកាត់បន្ថយការ ស្អុយរលួយនៃព្រៃឈើ និងសារពើរុក្ខជាតិនៅក្នុងទឹក ។ សំអាតកំទេចកំទីសេសសល់ក្នុង | OE/PO | មានបញ្ចូលនៅក្នុងតំលៃកិច្ចសន្យាអ្នកម៉ៅការ ។ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | របស់អាងស្តុក។ កាកសំណល់ដែលបោះចូលក្នុងប្រភពទឹក ឬ នៅកន្លែងទំនេរក្បែរប្រភពទឹកចេញពីបុគ្គលិកប្រតិបត្តិការអាចបំពុលទឹករបស់ទន្លេសេសានផងដែរ។ ក៏រិតរលាយអុកស៊ីសែនទាប ការបំពុលខ្ពស់ពីជីវសាស្ត្រ និង ប៉ារ៉ាម៉ែត្រនៃសារធាតុចិញ្ចឹម ឬ ដោយបាតុភូត euthophication (ការរីកលូតលាស់ យ៉ាងអាក្រក់នៃរុក្ខជាតិទឹក /ការ៉ះរសចង្រៃ) នឹងកើតឡើង។ នៅពេលខ្លះការរីកដុះដាលហួសហេតុនៃបាក់តេរីចម្លងរោគ វីរុស និង ពួកផ្តល់ជំរកឬវិចទ័រ ដែលទាក់ទង នឹងជំងឺ (ខ្យង មូស ។ល ។) អាចនឹងកើតមានឡើង។ ផលប៉ះពាល់ដោយប្រយោលដល់ សត្វ និង មនុស្សអាចបណ្តាល ពីការឆ្លងជំងឺ ដូចជាគ្រុនចាញ់ គ្រុនឈាម Shistosomasis ។ល។ | | | | ភូមិ និងផ្លូវខ្មោច សំអាតជីវម៉ាស់ ដែលមាននៅជាប់ខាងមុខទំនប់មួយគីឡូម៉ែត្រ និងសំអាតសារធាតុគីមីពុល ដែលសេសសល់ពីសង្គ្រាម ១៩៦០-១៩៧៥ ។<br>- ផ្តល់មធ្យោបាយគ្រប់គ្រងកាកសំណល់អោយបានគ្រប់គ្រាន់ រាប់បញ្ចូលទាំងបង្គន់អនាម័យនៅការដ្ឋានសាងសង់ និងនៅជំរុំស្នាក់នៅរបស់បុគ្គលិក កម្មករគំរោង។<br>- ត្រួតពិនិត្យគុណភាពទឹកនៅក្នុងអាងស្តុកអោយបានញឹកញាប់ ដើម្បីជៀសវាងផលប៉ះពាល់អាក្រក់បណ្តាលពីការរីកដុះដាល យ៉ាងអាក្រក់របស់ស្មៅទឹកចង្រៃ ឬ ពួកអាល់កាប្រផេះ ការបន្តពូជរបស់បាក់តេរី និង វីរុសនៅក្នុងអាងស្តុកទឹក។ | | |
| ហេតុប៉ះពាល់ទៅលើសត្វព្រៃ និង | ទំហំផ្ទៃអាងយ៉ាងធំ និង ជំរៅជ្រៅ (ទទឹង ១-៧គ.ម បណ្តោយ ៣០-៥០គ.ម និង ជំរៅ ២០-៣៥ម) នៃអាងស្តុកជាឧបសគ្គដល់ការធ្វើបំលាស់ទីរបស់សត្វព្រៃនៅក្នុងតំបន់។ | | ✓ | | - ហាមឃាត់ដាច់ខាតការទន្ទ្រានចូលទៅក្នុងព្រៃ/ជំរករបស់សត្វព្រៃក្នុងន័យការរានដីថ្មីសំរាប់កាន់កាប់ដីធ្លី ឬ ការបរបាញ់ ជាពិសេសនៅជុំវិញតំបន់តាំងទីលំនៅសារជាថ្មីរបស់គំរោងនេះ។ | OE/PO, MoE និង ភ្នាក់ងារអភិរក្សក្នុងតំបន់ | មានដាក់នៅក្នុងមូលនិធិបរិស្ថានប្រចាំឆ្នាំដែលម្ចាស់គំរោងនឹងបង់ជូនស្ថាប័នទទួល |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| ជំរកសត្វព្រៃ | តំបន់តាំងលំនៅសារជាថ្មីសំរាប់ភូមិស្រែគរ ភូមិស្រែស្រណុក និង ភូមិក្របីជ្រុំ នឹងបន្ថែមសំពាធដល់ជំរកសត្វព្រៃ និង សត្វព្រៃដែលនៅក្បែរតំបន់ ដោយសារការទន្ទ្រាន ពីអ្នកភូមិ ។ | | | | - ហាមបរបាញ់សត្វព្រៃនៅក្នុងតំបន់នេះ ដោយធ្វើសហប្រតិបត្តិការជាមួយភ្នាក់ងារការពារសត្វព្រៃសំរាប់កម្មវិធីការពារសត្វព្រៃនៅថ្នាក់តំបន់ និងថ្នាក់ជាតិ ក្រុមហ៊ុនអនុវត្តគំរោងនឹងចូលរួមគាំទ្រជាបច្ចេកទេស និង ថវិកា ដើម្បីការពារជំរកសត្វព្រៃ និង សត្វព្រៃនៅក្នុង និង នៅជុំវិញតំបន់គំរោង ។ | | ខុសត្រូវ (*) |
| ហេតុប៉ះពាល់ទៅលើវារីជីវ និង ជលផល | គំរោងរោងចក្រសេសានក្រោម ២ នឹងប៉ះពាល់ដល់ចលនាវារីជីវសាស្ត្រ ជាពិសេសត្រីនៅក្នុងទន្លេសេសាន និង ទន្លេស្រែពកដោយសារការសាងសង់ទំនប់កាត់តាមទន្លេ និង ប្រតិបត្តិការរបស់គំរោង។ សត្វនៅក្នុងទឹក និង ត្រីទាំងអស់នឹងមិនមានលទ្ធភាពធ្វើបំលាស់ទីឡើង និងចុះពីទំនប់បានទេ។ | | | ✓ | - ផ្តល់មធ្យោបាយសមស្របដើម្បីអោយត្រី និងវារីសត្វដទៃទៀតមានវត្តមានឡើងវិញ ក្នុងតំបន់គំរោង ដោយបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងភ្ញាស់ពូជត្រី ដើម្បីជួយថែរក្សាអោយមានតុល្យភាពត្រីនៅខាងលើ និងខាងក្រោមខ្សែទឹកនៃទីតាំងគំរោង។<br>- ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវត្រីខ្នាតមធ្យម (ដែលអាចភ្ញាស់ពូជត្រី ៥ ទៅ ១០ប្រភេទ និង ការបណ្តុះបណ្តាលប្រព័ន្ធវារីវប្បកម្ម (ការចិញ្ចឹមត្រីនៅក្នុងបែរនៅក្នុងទន្លេ និងនៅក្នុងស្រះ/ត្រពាំងក្នុងតំបន់គំរោង) និងកម្មវិធីកសិកម្ម ចិញ្ចឹមសត្វ (ជ្រូក គោ មាន់ ទា និង សត្វផ្សេងៗទៀត) ព្រមទាំងការដាំដំណាំរួមផ្សំមួយចំនួន នឹងត្រូវបានផ្តល់ដោយក្រុមហ៊ុន អនុវត្តគំរោង ទាំងបច្ចេកទេស និងថវិកាក្នុងរយៈពេលសមរម្យ ដែល | OE/PO, រដ្ឋបាលជលផល/ ក្រសួងកសិកម្ម | តំលៃការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនិង ភ្ញាស់កូនត្រីមានដាក់នៅខាងលើ<br>0.១ លានដុល្លាអាមេរិកសំរាប់ការភ្ញាស់កូនត្រី និងដំណើរការស្ថានីយ៍ ១៥ឆ្នាំ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | អាចធានាបានចំពោះបំលាស់ប្តូរនៃការផ្គត់ផ្គង់អាហារពីត្រី ធម្មជាតិ របស់អ្នកភូមិក្នុងតំបន់គំរោង។<br>- ក្រុមហ៊ុន នឹងសហការយ៉ាងល្អជាមួយរដ្ឋបាលជលផល មន្ទីរកសិកម្ម និងស្ថាប័នជាប់ទាក់ទងដទៃទៀត ដើម្បីអនុវត្តវិធានការខាងលើអោយទទួលបានលទ្ធផលដ៏គាប់ប្រសើរតាមការគ្រោងទុក។ | | និង ០,៣២៧ លានដុល្លាអាមេរិក ក្នុងមួយឆ្នាំសំរាប់កម្មវិធីគាំទ្រកសិកម្ម (រយៈពេលនៃវិធានការកាត់បន្ថយស្នើសុំ ៥ឆ្នាំ)** |
| ហេតុប៉ះពាល់ទៅលើពូជកំរ ឬ ពូជដែលកំពុងជួបគ្រោះថ្នាក់ | គំរោងនឹងធ្វើអោយមានការបាត់បង់យ៉ាងធ្ងន់ធ្ងរដល់ប្រភេទកំរចំនួន ៤ប្រភេទ គឺត្រីត្រសក់ ត្រីរមាស ត្រីស្នូក់ និងត្រីក្របី ដែលជាពូជត្រីជិតផុតពូជ និងកំពុងរងគ្រោះ និងប្រភេទកំរ ២ប្រភេទទៀតគឺ ត្រីប៉ាស៊ីអី និងត្រីប៉ាវ៉ាមុខពីរ (CITES) ដែលកំពុងមានវត្តមាន និងចាប់បាននៅក្នុង ទន្លេសេសាន និងទន្លេស្រែពក ។ ហើយអាចនឹងត្រូវបាត់បង់ទាំងស្រុង នៅក្នុងតំបន់គំរោង ឬបាត់បង់ថែមទៀតនៅផ្នែកខាងក្រោមនៃតំបន់គំរោង ដោយសារគំរោង | | ✓ | | - មជ្ឈមណ្ឌលស្រាវជ្រាវខាតបច្ចេមអំពីត្រីនឹងត្រូវផ្តល់ ដែលអាចផលិត នូវពូជត្រីដែលមានពូជដូចលក្ខខណ្ឌបច្ចុប្បន្ន និងអាចរស់នៅក្នុងតំបន់ទន្លេទាំងពីរបាន ហើយប្រលែងទៅកាន់ខ្សែទឹកខាងក្រោម និង ខ្សែទឹកខាងលើរបស់ទីតាំងគំរោង ជាមួយនឹងបរិមាណសមមូលទៅនឹងបរិមាណដែលអាចផ្តល់ទិន្នផលដូចដែលមានក្នុងលក្ខខណ្ឌបច្ចុប្បន្ន (មុនគំរោង) ឬ វិធីសាស្ត្រដទៃទៀតដែលអាចការពារពូជត្រីកំរ និង ដែលមានគ្រោះថ្នាក់នៅក្នុងទន្លេទាំងពីរ។ ការងារនេះក្រុមហ៊ុននឹងសហការយ៉ាងជិតស្និទជាមួយរដ្ឋបាលជលផល | OE/PO, រដ្ឋបាលជលផល | ៨០.០០០ ដុល្លា ក្នុង១ឆ្នាំ រយៈពេល ១០ឆ្នាំ |



Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | (ទំនប់) នឹងត្រូវកាត់ផ្តាច់ផ្លូវផ្លាស់ទីនៅក្នុងទន្លេទាំងពីរ ។<br>ការបាត់បង់ព្រៃជំរក អាងស្តុកទឹកធំ/វែង/ជ្រៅ គំរោងនឹងមានផលប៉ះពាល់ទៅលើពូងសត្វលើគោកដែលកំរ និង កំពុងរងគ្រោះថ្នាក់ ដូចជា គោព្រៃ ខ្លា ដំរី ទន្សោង ក្របីព្រៃ ខ្លាត្រី ខ្លាឃ្មុំខ្មៅ សត្វទោច កូខ្លួនខ្មៅ ក្ងោក បែតងត្នាត ។ | | | | ដើម្បីដោះស្រាយអោយមានប្រសិទ្ធិភាព ។<br>- អនុវត្តកម្មវិធីត្រួតពិនិត្យ ត្រី និងជលផល នៅក្នុងតំបន់គំរោង និងស្ថានីយ៍ផលិតពូជរយៈពេល ១០ឆ្នាំ ចាប់ផ្តើម ឆ្នាំ ២០១០ ។ | | |
| ហេតុប៉ះពាល់ទៅលើជីវភាពអ្នកនៅខ្សែទឹកខាងក្រោម និង នៅខ្សែទឹក | ប្រជាជនរស់នៅតាមដងទន្លេសេសាន និង ទន្លេ ស្រែពកពឹងផ្អែកទៅលើកសិដ្ឋាន នេសាទ ការប្រមូលអនុផលព្រៃឈើ និង ការចិញ្ចឹមសត្វ (ក្របី និង សត្វពាហនៈ) ។ សកម្មភាពទាំងនេះដើរតួ យ៉ាងសំខាន់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេនៅក្នុងតំបន់គំរោង ប៉ុន្តែសកម្មភាពនេសាទនាពេលបច្ចុប្បន្នបានក្លាយជាស្នូលសំរាប់អ្នកភូមិនៅក្នុងតំបន់គំរោង ខាងលើ និង ខាងក្រោម | | ✓ | | - សហការជាមួយភ្នាក់ងារអភិរក្សសត្វព្រៃ និង ផ្តល់ថវិកា ការពារជំរកបក្សីដែលស្ថិតនៅក្បែរតំបន់គំរោង រាប់បញ្ចូលទាំងជំរកបក្សីផងដែរ (ជំរកដែលមានស្រាប់ និង ជំរកថ្មី) នៅក្នុងដែនដីខេត្តស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និង ខេត្តក្រចេះ ។ | OE/PO, និង MoE | នៅក្នុងមូលនិធិបរិស្ថានប្រចាំឆ្នាំដែលម្ចាស់គំរោងនឹងបង់ជូនស្ថាប័នទទួលខុសត្រូវ (*) |
| | | | | | - ម្ចាស់គំរោងនឹងផ្តល់វគ្គបណ្តុះបណ្តាលសមស្រប ឬ ជំនាញថ្មីៗ និង ការស្តារចំណូលឡើងវិញដល់គ្រួសារ និង ប្រជាជនដែលរងគ្រោះ (អ្នកបើកបរកាណូត និង អ្នកនេសាទ) ។ តំលៃនៃការបណ្តុះបណ្តាល និង ការស្តារចំណូលឡើងវិញនឹងត្រូវផ្តល់អោយពីក្រុមហ៊ុន | OE/PO, IFC/MEF | មាននៅក្នុងកម្មវិធីការស្តារជីវភាពចំពោះគ្រួសារដែលរងផលប៉ះពាល់ផ្ទាល់ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| ខាងលើ | ខ្សែទឹក។<br>គំរោងនឹងប៉ះពាល់ទៅលើជីវភាពរបស់សហគមន៍ នៅខាងក្រោមខ្សែទឹកផងដែរ តាមរយៈនៃការប៉ះពាល់ដល់សុខភាព (ទឹកខ្វះគុណភាព) ការថយចុះ ផលិតកម្មនេសាទ ការបំផ្លាញសួនបន្លែនៅតាមច្រាំងទន្លេ ឬ មាត់ទន្លេ និង ពេលខ្លះបំផ្លាញទ្រព្យសម្បត្តិ ឬ សំលាប់សត្វ និង អ្នកភូមិដោយសារការផ្លាស់ប្តូររបបធារទឹក និង ជំនន់ភ្លាមៗបណ្តាលពីការបញ្ចេញទឹកពីទំនប់នៅក្នុងដំណាក់កាលប្រតិបត្តិ។ | | | | អនុវត្តគំរោង។ ចំនួនគ្រួសារ និង ប្រជាជនរងគ្រោះត្រូវបានរាប់ដោយផ្អែកតាមលទ្ធផលនៃសិក្សា ពីការតាំងទីលំនៅសារជាថ្មី ដែលមាននៅក្នុងរបាយការណ៍ដោយឡែក ដោយ PECC-1 ។ | | ក្នុងកញ្ចប់ថវិកាសំរាប់តាំងលំនៅសារជាថ្មី |
| | | | | | - ម្ចាស់គំរោងនឹងទទួលផ្តល់សំណងដល់គ្រួសារប៉ះពាល់មិនផ្ទាល់ ដែលរស់នៅខ្សែទឹកខាងលើនៃតំបន់គំរោងនៅតាមដងទន្លេទាំងពីរ ក្នុងខេត្តរតនៈគីរី និងមណ្ឌលគីរី ដោយផ្តល់ជាកម្មវិធីគាំទ្រសិកម្ម ដូចជា ការចិញ្ចឹមសត្វ ការដាំដុះ ស្រូវ បន្លែ និងដំណាំផ្សេងៗទៀត ព្រមទាំងឥណទានជនបទ។ ក្រុមហ៊ុនត្រូវទទួលបន្ទុកថវិកាទាំងអស់ សំរាប់អ្នកបច្ចេកទេស និងផ្តល់នូវពូជដែលជួយអោយប្រជាជន ទាំងនោះទទួលបាននូវនិរន្តរភាពក្នុងការចិញ្ចឹមជីវិតជំនួសអោយការពឹងផ្អែកលើធនធានធម្មជាតិទាំងស្រុងនោះវិញ។ | OE/PO, ក្រសួងកសិកម្ម | ០,៣២៣ លានដុល្លាអាមេរិកក្នុងមួយឆ្នាំសំរាប់កម្មវិធីគាំទ្រកសិកម្ម (រយៈពេលនៃវិធានការកាត់បន្ថយស្នើសុំ ១០ឆ្នាំ)** |
| | | | | | - ត្រួតពិនិត្យគុណភាពទឹកអោយបានទៀងទាត់ក្នុងអាងស្តុកដើម្បីជៀសវាងផលប៉ះពាល់មិនល្អបង្កដោយការរីកលូតលាស់យ៉ាងអាក្រក់របស់ស្មៅទឹកចង្រៃ ឬការរីកលូតលាស់យ៉ាងអាក្រក់នៃអាល់ហ្គាប្រផេះ បាក់តេរីបង្ករោគ និង ការបន្តពូជពួកវីរុសក្នុងអាងស្តុក។ | OE/PO | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | - ផ្តល់ពីកាលវិភាគបញ្ចេញទឹកអោយបានគ្រប់គ្រាន់ និង ទាន់ពេលវេលាដល់សហគមន៍នៅខ្សែទឹកខាងក្រោម ដើម្បីជៀសវាងគ្រោះថ្នាក់ដល់សុខភាព ទ្រព្យសម្បត្តិ និង ការរស់នៅ។ | | |
| **ហេតុប៉ះពាល់ទៅលើការផ្គត់ផ្គង់ទឹក** | ការបញ្ចេញទឹកពីគំរោងក្នុងដំណាក់កាលប្រតិបត្តិ អាចប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកនៅខ្សែទឹកខាងក្រោម ជាពិសេសសហគមន៍ភ្លុក និង ទីរួមខេត្តស្ទឹងត្រែង ប្រសិនបើគុណភាពទឹកនៅក្នុងអាងមានភាពកខ្វក់។ | ✓ | | | - ត្រួតពិនិត្យគុណភាពទឹកអោយបានទៀងទាត់ នៅក្នុងអាងស្តុក ដើម្បីជៀសវាងផលប៉ះពាល់មិនល្អ បណ្តាលពីការរីកលូតលាស់យ៉ាងអាក្រក់របស់ស្មៅ ទឹកចង្រៃ ឬ អាល់ហ្គាប្រផេះ បាក់តេរីបង្ករោគ និង ការបន្តពូជវីរុសនៅក្នុងអាងស្តុក។<br>- ត្រូវធ្វើសកម្មភាពអោយបានទាន់ពេលដើម្បីការពារគ្រោះថ្នាក់ ខ្ពស់ពីគុណភាពទឹក ដែលកើតនៅឡើងក្នុងអាងស្តុក។ | OE/PO, DoE | ១០០០ ដុល្លាអាមេរិក/ឆ្នាំ (អនុវត្តពេញក្នុងរយៈពេលវិនិយោគ) |
| **ហេតុប៉ះពាល់ទៅលើទីកន្លែងទេសចរណ៍** | គំរោងនឹងប៉ះពាល់លើទីកន្លែងទេសចរណ៍នៅខ្សែទឹកខាងក្រោម ជាពិសេសទឹកធ្លាក់នៅក្នុងឃុំភ្លុក។ | ✓ | | | - សហការជាមួយអាជ្ញាធរក្នុងតំបន់ និងមន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង ដើម្បីរកកន្លែងទេសចរណ៍ផ្សេងទៀតដែលនៅក្បែរតំបន់គំរោង ហើយកែលំអ /អភិវឌ្ឍន៍ ដើម្បីផ្តល់ប្រាក់ជំនួយដល់កន្លែងទឹកធ្លាក់ ដែលបាត់បង់ដោយគំរោង។ | OE/PO | បញ្ចូលក្នុងតំលៃវិនិយោគគំរោង។ |
| **ហេតុប៉ះពាល់ទៅ** | គំរោងអាចប៉ះពាល់ដល់សុខភាពសហគមន៍ក្នុងដំណាក់កាលប្រតិបត្តិ ដូចជាការឆ្លងជំងឺ | | ✓ | | - ហាមឃាត់បុគ្គលិកគំរោងកុំអោយចម្លង ឬ ធ្វើអោយរាលដាលជំងឺចូលទៅសហគមន៍មូលដ្ឋាន ផ្តល់ប៉ុស្តិ៍ថែទាំ | OE/PO | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **លើសុខភាពសាធារណៈ** | សង្គមមាន HIV/AIDS, ជំងឺកាមរោគជាដើមពីបុគ្គលិកគំរោង។ ការចាក់ថ្នាំញៀន និងការធ្វើចរាចរណ៍ថ្នាំញៀនពីបុគ្គលិកគំរោង ក្នុងសហគមន៍មូលដ្ឋាន ក៏អាចប៉ះពាល់យ៉ាងអាក្រក់ផងដែរដល់ប្រជាជន។ នៅពេលអាគារផលិតថាមពលចាប់ផ្តើមដំណើរការជាថ្មីម្តងទៀត ធារទឹកនិងនីវ៉ូទឹកនៅខ្សែទឹកក្រោមនៃអាគារផលិតថាមពលនឹងកើនយ៉ាងឆាប់រហ័ស ហើយអាចគ្រោះថ្នាក់ដល់មនុស្ស និង សត្វ។ | | | | សុខភាពនៅក្នុងសហគមន៍ក្បែរតំបន់គំរោងពិនិត្យសុខភាពបុគ្គលិកគំរោងអោយទៀងទាត់និងព្យាបាលប្រសិនបើឃើញមានបញ្ហាសុខភាព។<br>- ផ្តល់អាងខ្សែទឹកខាងចុងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីកាត់បន្ថយធារទឹក និងកំពស់ទឹកពីអាគារផលិតថាមពល កំឡុងពេលបញ្ចេញទឹកយ៉ាងគំហុក។<br>- ផ្សព្វផ្សាយពីកាលវិភាគប្រតិបត្តិ និង ការបញ្ចេញទឹកពីគំរោង អោយបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់សហគមន៍នៅ ខ្សែទឹកខាងក្រោម ដើម្បីជៀសវាងគ្រោះថ្នាក់ដល់ទ្រព្យសម្បត្តិ និង អាយុជីវិត។ | | |

**ចំណាំ:** (*) មូលនិធិបរិស្ថានប្រចាំឆ្នាំបានស្មើនឹង ០,៥ លាន USD; ម្ចាស់គំរោងនឹងត្រូវបង់ប្រចាំឆ្នាំទៅ ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីស្តារ និងគ្រប់គ្រងបរិស្ថានដែលរងផលប៉ះពាល់ ដោយសារគំរោងវារីអគ្គិសនីសេសានក្រោម ២។ រាជរដ្ឋាភិបាលនឹងប្រើប្រាស់មូលនិធិនេះដើម្បីទ្រទ្រង់ដល់កម្មវិធីអភិរក្សព្រៃឈើ និង សត្វព្រៃនៅក្នុងតំបន់ (ខេត្តស្ទឹងត្រែង រតនៈគីរី និងមណ្ឌលគីរី)។

** តំលៃលើកឡើងលំអិតសំរាប់វិធានការកាត់បន្ថយមានពណ៌នានៅឧបសម្ព័ន្ធទី៦ ។

## ៨.៣ កម្មវិធីពិនិត្យតាមដានបរិស្ថាន

ការតាមដានលើប៉ារ៉ាម៉ែត្រមួយចំនួនពីហេតុប៉ះពាល់បរិស្ថានបណ្តាលមកពីគំរោង មុនពេលសាងសង់ ពេលសាងសង់ និង ពេលដំណើរការត្រូវទាមទារជាចាំបាច់។ ស្ថាប័នទទួលខុសត្រូវ និង តំលៃសំរាប់អនុវត្តការពិនិត្យតាមដាន មានបញ្ចូលនៅក្នុងកម្មវិធីតាមដាន សូមមើលតារាងទី ៥៩។ ការប៉ាន់ស្មានពីតំលៃលំអិតមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៦។

**តារាងទី ៥៩:** កម្មវិធីពិនិត្យតាមដានបរិស្ថាន

| វិធានការបន្ធូរបន្ថយ | ប៉ារ៉ាម៉ែត្រត្រូវតាមដាន | ទីកន្លែង | ប្រេកង់ | ស្ថាប័នទទួលខុសត្រូវ | តំលៃ, US$ |
|---|---|---|---|---|---|
| ***ដំណាក់កាលមុនសាងសង់*** | | | | | |
| កាត់បន្ថយទំហំគំរោងដើម្បីបន្ថយអោយបានអប្បបរិមានូវផ្ទៃដីព្រៃលិចទឹក ដីកសិកម្ម ដីព្រៃសម្បទានដែលមានស្រាប់ និង តំបន់លំនៅដ្ឋាននៃឃុំទាំងបួនក្នុងស្រុកសេសាន។ ទីតាំងទំនប់ត្រូវសាងសង់នៅទីតាំងទី ១ ចំងាយ ១,៥គ.ម ពីចំនួចប្រសព្វទន្លេសេសាន និង ទន្លេស្រែពក។ ទីលំនៅថ្មីគួរជ្រើសរើសនៅកន្លែងដែលគ្មានជម្លោះ/គ្រោះថ្នាក់ដល់ធនធានសង្គម និង បរិស្ថាននៅក្នុងតំបន់។ | ត្រួតពិនិត្យប្លង់វិស្វកម្ម និង គ្រោងប្លង់របស់គំរោងចុងបញ្ចប់។ | ការិយាល័យគំរោង | ម្តងសំរាប់ពង្រាងប្លង់បញ្ចប់ និង ម្តងសំរាប់ប្លង់បញ្ចប់ | DE/PO, GDE, DoE, IRC | គ្មានតំលៃ |
| | ពិនិត្យមើលគំនូរព្រៀង ធ្វើអោយប្រាកដថាទីតាំងទំនប់មានចំងាយ ១,៥ គ.ម ពីចំនុចប្រសព្វរបស់ទន្លេ។ | ការិយាល័យគំរោង | ម្តងសំរាប់ពង្រាងប្លង់បញ្ចប់ និង ម្តងសំរាប់ប្លង់បញ្ចប់ | DE/PO, GDE, DoE, IRC | គ្មានតំលៃ |
| | តាមដានតំបន់តាំងទីលំនៅថ្មីដើម្បីពិនិត្យពីផលប៉ះពាល់លើសង្គម និង បរិស្ថានតាមទីកន្លែង | ការិយាល័យគំរោង និង ការពិនិត្យដល់ទីកន្លែងនៅការដ្ឋានដែលបានស្នើសុំ | ម្តងសំរាប់ពង្រាងប្លង់បញ្ចប់ និង ម្តងសំរាប់ប្លង់បញ្ចប់ | DoE, IRC, និង អាជ្ញាធរតំបន់ | ១៣២០ |

Draft

| | | | | | |
|---|---|---|---|---|---|
| ផ្លូវវាង ផ្លូវចូល និង ទីកន្លែងផ្លាស់ប្តូរលំនៅដ្ឋានគួរជ្រើសរើសនៅកន្លែងដែលមិនមានផលប៉ះពាល់អាក្រក់ដល់ធនធានធម្មជាតិ និង សង្គមនៅក្នុងតំបន់ ។ | ពិនិត្យផ្លូវវាង ផ្លូវចូល និង តំបន់តាំងទីលំនៅថ្មី | ការិយាល័យគំរោង និង ពិនិត្យដល់ទីកន្លែងនៅការដ្ឋានដែលបានស្នើសុំ | ម្តងសំរាប់ពង្រាងប្លង់បញ្ចប់ និង ម្តងសំរាប់ប្លង់បញ្ចប់ | DE/PO, DPWT, និង DoE | ១៦០ |
| វចនាសម្ព័ន្ធឆ្លងកាត់របស់ត្រី ឬ មធ្យោបាយផ្សេងទៀតត្រូវផ្តល់អោយដើម្បីអោយត្រី និង វារីសត្វដទៃទៀតធ្វើអន្តោប្រវេស្តន៍ឡើង និង ចុះកាត់ទំនប់បាន ។<br>ឬ មជ្ឈមណ្ឌលស្រាវជ្រាវ គឺជាជំរើសមួយដើម្បីធ្វើអោយមានតុល្យភាពនៅខ្សែទឹកលើ និង ក្រោមក្នុងទន្លេទាំងពីរ ។<br>ឬ សងដល់ការបាត់បង់ត្រីនៅក្នុងទន្លេទាំងពីរ (សេសាន និង ស្រែពក) ដើម្បីទ្រទ្រង់ជីវភាពរបស់ប្រជាជនមូលដ្ឋានដែលរស់នៅតាមដងទន្លេ ។ | ពិនិត្យប្លង់វិស្វកម្មបញ្ចប់ ឬ មជ្ឈមណ្ឌលស្រាវជ្រាវត្រីដែលបានស្នើ ឬ សំណងដើម្បីផ្គត់ផ្គង់ជីវភាពរបស់ប្រជាជនមូលដ្ឋានតាមដងទន្លេ ។ | ការិយាល័យគំរោង | ម្តងសំរាប់ពង្រាងប្លង់បញ្ចប់ និង ម្តងសំរាប់ប្លង់បញ្ចប់ | DE/PO, GDE, រដ្ឋបាលជលផល និង DEIA/MoE | គ្មានតំលៃ |
| ក្រុមហ៊ុនអនុវត្តគំរោងរួមជាមួយ MIME ត្រូវសហការជាមួយស្ថាប័នទទួលខុសត្រូវលើដី និង ព្រៃសម្បទានដើម្បីដោះស្រាយ | ពិនិត្យមើលរបាយការណ៍គំរោងលំអិតដើម្បីប្រាកដថាគណៈកម្មការដំណោះស្រាយសំរាប់ជម្លោះដីធ្លីបានរៀបចំរួច | ការិយាល័យគំរោង និង ពិនិត្យដល់ទីកន្លែងនៅការដ្ឋាន | ម្តងសំរាប់ពង្រាងប្លង់បញ្ចប់ និង ប្រាំដងសំរាប់ប្លង់បញ្ចប់ និង ដំណោះ | DE/PO, IRC/MEF, MAFF, DLMUPC, និង | ៤៤០០ |

| | | | | | |
|---|---|---|---|---|---|
| ជម្លោះដីធ្លីមុនគំរោងសាងសង់ ។ | វាស់និងធ្វើការយ៉ាមានប្រសិទ្ធិភាពជាមួយក្រុមហ៊ុនដី និង ព្រៃសម្បទាន ។ | ដែលបានស្នើសុំ | ស្រាយចប់សព្វគ្រប់ | DEIA/MoE | |
| កន្លែងតាំងទីលំនៅថ្មីត្រូវរៀបចំនៅកន្លែង និង ទំហំសមរម្យ សំរាប់គ្រួសារ និង ប្រជាជនដែលរងផលប៉ះពាល់ ។ សកម្មភាពផ្លាស់ទីលំនៅគួរត្រូវធ្វើដោយការចរចារសន្តិវិធីជាមួយគ្រួសារ/ប្រជាជនរងផលប៉ះពាល់ និង សំណងសមស្របដូចតំលៃជាក់ស្តែងនៅក្នុងទីផ្សារតំបន់ ។ ប្រសិទ្ធិភាពនៃកាលបរិច្ឆេទសំណងគួរធ្វើ អោយបានមុនសកម្មភាពសាងសង់ ។ លើសពីនេះទៅទៀតសំណង និង សកម្មភាព ផ្លាស់ទីលំនៅគួរធ្វើឡើង ប៉ុន្តែធ្វើតាមលទ្ធផលជាក់ស្តែងនៃការសិក្សាដែលមានរៀបរាប់នៅក្នុងរបាយការណ៍តាំងទីលំនៅសារជាថ្មី ។ | ពិនិត្យមើលសំណង និង ការអនុវត្តន៍ផែនការសកម្មភាពផ្លាស់ប្តូរទីលំនៅអោយមានប្រសិទ្ធិភាពដូចលទ្ធផលជាក់ស្តែងលើការសិក្សាពីការផ្លាស់ទីលំនៅ ។ | ការិយាល័យគំរោង និង ពិនិត្យដល់ទីកន្លែងនៅការដ្ឋានដែលបានស្នើសុំ | ម្តងសំរាប់ពង្រាងបួងបញ្ចប់ និង ១០ដងសំរាប់បួងបញ្ចប់ និង ដំណោះស្រាយចប់សព្វគ្រប់ | DE/PO, IRC/MEF, អាជ្ញាធរមូលដ្ឋាន, NGOs (3S rivers, CEPA), និង DEIA/MoE | ៧២៦០ |
| ***ដំណាក់កាលសាងសង់*** | | | | | |
| ការស្ថាបនាប្រឡាយបង្វែរនៅទីតាំងទំនប់គួរផ្តល់អោយដោយមានទំហំគ្រប់គ្រាន់ ដើម្បី | ត្រួតពិនិត្យការបញ្ចេញចារទឹក វិមាត្រប្រឡាយបង្វែរដែលអាចធ្វើនាវាចរណ៍ | នៅការដ្ឋានសំណង់ប្រឡាយបង្វែរ | ពីរដងនៅក្នុងដំណាក់កាលសាងសង់ដំបូង និង | CE, DWRAM, DPWT, និង | ៣០៨០ |

| | | | | | |
|---|---|---|---|---|---|
| បញ្ចេញទឹកទៅខ្សែទឹកក្រោមជៀសវាងការផ្លាស់ប្តូរធារទឹកធំធេងនៅក្នុងទន្លេ ជំនន់នៅខ្សែទឹកលើ និង អាចប្រើប្រាស់ជាផ្លូវនាវាចរណ៍បណ្តោះអាសន្ន ។ | របស់ទូកតូចៗ ។<br>ពិនិត្យពីដំណើរការរបស់ប្រឡាយ | | ប្រចាំត្រីមាសនៅក្នុងកំឡុងពេលសាងសង់ទាំងមូល | DoE | |
| ផ្តល់អោយមានប្រព័ន្ធបង្ហូរច្រោះគ្រប់គ្រាន់នៅតាមដងផ្លូវចូលទៅតំបន់គំរោង ។ | ពិនិត្យប្រព័ន្ធបង្ហូរច្រោះអោយច្បាស់ថា ក្រុមហ៊ុនអនុវត្តគំរោង និង អ្នកម៉ៅការបានផ្តល់គ្រប់គ្រាន់ ។ | នៅតាមកន្លែងសាងសង់ផ្លូវ និង កន្លែងផ្សេងទៀត | ប្រចាំត្រីមាសនៅក្នុងកំឡុងពេលសាងសង់ទាំងមូល | CE, DWRAM, និង DoE | ១៦០០ |
| វិធានការត្រួតពិនិត្យសំណឹក និង កករសមស្រប ( អណ្តូងស្ទាក់ និង ក្រណាត់/ប្លាស្ទិកខៀវ ដែលមានក្រលាសំណាញ់តូចៗ) គួរដាក់អោយត្រូវកន្លែងដើម្បីជៀសវាងការហូររងកករពីការដ្ឋាននៅរដូវវស្សា ។ | ត្រួតពិនិត្យទីកន្លែង/វិធីសាស្ត្រការពារការរងកករ និង សំណឹក ត្រូវប្រាកដថាវិធានការបន្ធូរបន្ថយបានអនុវត្តត្រឹមត្រូវ ។ | នៅការដ្ឋានសំណង់ | ប្រចាំខែនៅក្នុងរដូវភ្លៀងពេញពេលសាងសង់ | CE, DWRAM, និង DoE | ១៦០០ |
| ផ្តល់ទីកន្លែងគ្រប់គ្រងកាកសំណល់គ្រប់គ្រាន់រាប់បញ្ចូលទាំងបង្គន់អនាម័យ នៅការដ្ឋានសាងសង់ និង កន្លែងរស់នៅពេលសាងសង់ ។ | ពិនិត្យទីកន្លែងគ្រប់គ្រងកាកសំណល់ និង ដំណើរការប្រើប្រាស់របស់វាសំរាប់គំរោង ។ | នៅការដ្ឋានសំណង់និងជំរុំកម្មករ /បុគ្គលិក | ប្រចាំត្រីមាសនៅក្នុងកំឡុងពេលសាងសង់ទាំងមូល | DoE | ៨០០ |
| ការត្រួតពិនិត្យគុណភាពទឹកនៅខាងលើខ្សែទឹក និង ខាងក្រោមខ្សែទឹកនៃតំបន់គំរោងគួរធ្វើឡើងអោយបានទៀងទាត់ដើម្បីធានា | ពិនិត្យ/ឆែកមើលគុណភាពទឹក ។<br>ប៉ារ៉ាម៉ែត្រ ចំនួន ១០ នឹងត្រូវចាប់យក | នៅ ៦ ស្ថានីយ៍តាមទន្លេទាំងពីរ អោយដូច/នៅក្បែរទីតាំង | ប្រចាំត្រីមាសពេញក្នុងដំណាក់កាលសាងសង់ | DPC និង DoE | ២០០០០ |

| | | | | | |
|---|---|---|---|---|---|
| បានថាគុណភាពទឹកនៅពេលសាងសង់មិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សត្វដែលរស់ក្នុងទឹក និង ដល់មនុស្ស ។ | សំរាប់ត្រួតពិនិត្យដូចជា pH Conductivity or Total dissolved solid (TDS), DO, $BOD_5$, COD, Tot-N, Tol-P, $NO_3$ -N, $PO_4$ –P, Tot-Coliform ជាដើម ។ | ដែលចាប់យកនៅក្នុងការសិក្សាជាមូលដ្ឋាន | | | |
| គេគួរប្រើប្រាស់គ្រឿងចក្រសំណង់ដែលមានគុណភាពល្អជាមួយនឹងការបំពុលខ្យល់តិចបំផុតតាមដែលអាចធ្វើបាន ។ សារធាតុបំផ្ទុះ និង បច្ចេកទេសសមស្របដើម្បីមិនអោយមានការបំពុលខ្ពស់សាយភាយចូលទៅក្នុងបរិយាកាស ហើយធ្វើឡើងតែនៅពេលថ្ងៃប៉ុណ្ណោះ ។ | ពិនិត្យ/តែកមើលគុណភាពខ្យល់ដែលសាយភាយចេញពីសកម្មភាពសាងសង់ ធ្វើអោយប្រាកដថាគ្មានគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស ព្រមទាំងសត្វនៅក្នុងតំបន់គំរោង ។ ប៉ារ៉ាម៉ែត្រដែលត្រូវវាស់វែង: TSP, NO2, SO2, CO, និង សំលេង ។ | នៅការដ្ឋានដែលមានសកម្មភាពខ្លាំង និង កន្លែងយកថ្ម ជាអនុសាសន៍គួរចាប់យកពីរសំណាក | រៀងរាល់ ៦ ខែ | DoE និង DPC | ១៥១២០ |
| ការកាប់ព្រៃឈើគួរធ្វើឡើងក្នុងរង្វង់តំបន់គំរោងដែលសកម្មភាពសាងសង់តំរូវអោយមានប៉ុណ្ណោះ ។ | ត្រួតពិនិត្យពីការកាប់ព្រៃឈើសំរាប់គំរោងទៅតាមការកំណត់ត្រឹមតំរូវការរបស់គំរោងពិតប្រាកដ ។ | នៅការដ្ឋានសាងសង់ និង នៅក្នុងផ្ទៃអាង | ប្រចាំសប្តាហ៍ ឬ ប្រចាំខែ ក្នុងការកាប់ឆ្ការសំរាប់ការដ្ឋានសំណង់ និង ការឆ្ការនៅក្នុងអាងស្តុក ។ | រដ្ឋបាលព្រៃឈើស្រុក, សមាជិកសហគមន៍ព្រៃឈើ | ៦០០០ |
| ហាមឃាត់កម្មករសំណង់មិនអោយចូលក្នុងព្រៃដើម្បីបរបាញ់ ឬ កាប់ឈើដាច់ខាត ។ | ពិនិត្យក្នុងតំបន់គំរោងដើម្បីធានាថាមិនមានការរានដីថ្មី ឬ ការបរបាញ់ | នៅក្បែរការដ្ឋានសំណង់ និង ជំរំរស់នៅ | | អាជ្ញាធរមូលដ្ឋាន, គណៈកម្មការសហ | |

Draft

| | | | | | |
|---|---|---|---|---|---|
| | ខុសច្បាប់ពីបុគ្គលិកគំរោងទេ។ | | | គមនីព្រៃឈើ | |
| ផ្តល់សម្បទានដើម្បីពង្រឹងកម្មវិធីអភិរក្សព្រៃឈើ និង ជំរកសត្វព្រៃនៅក្នុងតំបន់ដោយរាប់បញ្ចូលទាំងការធ្វើសហប្រតិបត្តិការ និង ផ្តល់ថវិកាដល់រដ្ឋបាលព្រៃឈើ និង ភ្នាក់ងារអភិរក្សដទៃទៀត ដើម្បីការពារព្រៃឈើ និង សត្វព្រៃនៅក្នុង និង នៅជុំវិញតំបន់គំរោង។ | ពិនិត្យពីថវិកាសំរាប់ពង្រឹងកម្មវិធីអភិរក្សព្រៃឈើ និង ជំរកសត្វព្រៃថាបានបង់ចំណាយបានទៀងទាត់។ | នៅការិយាល័យគំរោង នៅភ្នំពេញ | ប្រចាំឆ្នាំ | MEF, MAFF, MoE, និង ភ្នាក់ងារអភិរក្ស | គ្មាន |
| វិធានការត្រួតពិនិត្យសំណឹក និង កករសមស្រប (អណ្តូងស្ទាក់ និង ក្រណាត់/ប្លាស្ទិកខៀវ ដែលមានក្រលាសំណាញ់តូចៗ) គួរដាក់អោយត្រូវកន្លែងដើម្បីជៀសវាងការហូររងកករពីការដ្ឋានសំណង់នៅរដូវវស្សា។ | ពិនិត្យពីវិធីសាស្ត្រ និង ទីកន្លែងការពារ | នៅការដ្ឋានសំណង់ | ប្រចាំសប្តាហ៍ ឬ ប្រចាំខែ ក្នុងរយៈពេលសាងសង់ | DoE និង DWRAM | ៦០០០ |
| ត្រូវហាមឃាត់សកម្មភាពនេសាទខុសច្បាប់របស់បុគ្គលិក និង កម្មករគំរោង។ | ពិនិត្យមើលសកម្មភាពនេសាទខុសច្បាស់ពីបុគ្គលិកគំរោង | នៅតំបន់គំរោង | ប្រចាំខែ ក្នុងរយៈពេលសាងសង់ | រដ្ឋបាលជលផលស្រុក និង ក្រុមប្រឹក្សាឃុំ | ៤៨០០ |
| ថែទាំអោយបានញឹកញាប់ផ្លូវដែលមាន និង ផ្លូវចូលដែលប្រើប្រាស់សំរាប់គំរោង ដើម្បី | ពិនិត្យពីផ្លូវចូល និង ផ្លូវដែលមានដែលប្រើប្រាស់ដោយគំរោង | នៅតាមផ្លូវប្រើប្រាស់ដោយគំរោង | ប្រចាំត្រីមាសក្នុងរយៈពេលសាងសង់ | DPWT, DoE | ១៦០០ |

Draft

| | | | | | |
|---|---|---|---|---|---|
| ធានាបានពីដំណើរការល្អពេញក្នុងរយៈពេលសាងសង់ ។ | | | | | |
| ផ្តល់ស្លាកសញ្ញាចរាចរណ៍អោយបានគ្រប់គ្រាន់តាមបណ្តោយផ្លូវជាតិលេខ #៧៨ និង ផ្លូវចូលទៅតំបន់គំរោង ។ | ពិនិត្យមើលការរៀបចំចរាចរណ៍ និង ស្លាកសញ្ញា | នៅការដ្ឋានសំណង់ និង តាមបណ្តោយផ្លូវ | | | |
| អប់រំអ្នកបើកបររបស់គំរោងដើម្បីអោយកំណត់ល្បឿនបើកបរនៅតំបន់លំនៅដ្ឋាន ឬកន្លែងដែលមានមនុស្សកកកុញ ។ | ពិនិត្យមើលពីលក្ខណៈចរាចរ | នៅតាមផ្លូវក្នុងតំបន់គំរោង | | | |
| ***ដំណាក់កាលប្រតិបត្តិ*** | | | | | |
| បញ្ជាក់ព័តិមានអោយបានគ្រប់គ្រាន់ពីកាលវិភាគប្រតិបត្តិការ និង ការបញ្ចេញធារទឹកខ្ពស់បំផុតដល់សហគមន៍នៅខ្សែទឹកក្រោមដើម្បីជៀសវាង គ្រោះថ្នាក់ណាមួយដល់ទ្រព្យសម្បត្តិនៅលើ ច្រាំងទន្លេ និង ជីវិតមនុស្សព្រមទាំងសត្វ ។ | ពិនិត្យពីកាលវិភាគដំណើរការថាបានដាក់បានត្រឹមត្រូវ និង ផ្សព្វផ្សាយគ្រប់គ្រាន់ដល់សហគមន៍ក្រោមខ្សែទឹក | នៅការិយាល័យប្រតិបត្តិគំរោង | ប្រចាំត្រីមាស | DWRAM, CEPA, បណ្តាញទន្លេ 3S | គ្មានតំលៃ |
| អនុវត្តការតាមដានពីវារីសត្វ និង វារីរុក្ខជាតិនៅខ្សែទឹកក្រោមរបស់គំរោងក្នុងដំណាក់កាលប្រតិបត្តិ ។ | ពិនិត្យពីការស្រាវជ្រាវលើវារីសត្វ និង វារីរុក្ខជាតិថាត្រូវបានអនុវត្ត | នៅការិយាល័យគំរោង និង ក្រោមខ្សែទឹករបស់ទីតាំងទំនប់ | ប្រចាំឆ្នាំក្នុងរយៈពេលដំណើរការ ៥ ឆ្នាំ ដំបូង | រដ្ឋបាលជលផល, រដ្ឋបាលស្រុក | ២៥០០ |

| | | | | | |
|---|---|---|---|---|---|
| ហាមឃាត់ការទន្ទ្រានចូលព្រៃ/ជំរកសត្វព្រៃ ក្នុងន័យរានកាន់កាប់ដីថ្មីឬបរបាញ់ដាច់ខាត ។ | ពិនិត្យនៅក្នុងតំបន់គំរោងដើម្បីប្រាកដថាមិនមានការរានដីថ្មី ឬ ការបរបាញ់ខុសច្បាប់ពីបុគ្គលិកគំរោងទេ ។ | នៅតំបន់គំរោង និង ជុំវិញតំបន់តាំងទីលំនៅថ្មីដោយគំរោង | ប្រចាំត្រីមាស | រដ្ឋបាលព្រៃឈើ, អាជ្ញាធរមូលដ្ឋាន និង ភ្នាក់ងារ អភិរក្សនៅក្នុង តំបន់ | ប្រើប្រាស់មូលនិធិបរិស្ថានដែលផ្តល់នៅខាងលើ |
| ត្រួតពិនិត្យគុណភាពទឹកក្នុងអាងស្តុកអោយបានទៀងទាត់ដើម្បីជៀសវាងផលប៉ះពាល់អាក្រក់បង្កដោយការដុះលូតលាស់ហួសកំរិតរបស់ស្មៅទឹកចង្រៃ ឬ ពួកអាកាប្រផេះ បាក់តេរី និង វីរុសបង្ករោគដែលបន្តពូជក្នុងអាងស្តុក ។ | ពិនិត្យ/តែកមើលគុណភាពទឹក ។ *ប៉ារ៉ាម៉ែត្រ ចំនួន ១០ នឹងត្រូវចាប់យកសំរាប់ត្រួតពិនិត្យដូចជា pH Conductivity or Total dissolved solid (TDS), DO, $BOD_5$, COD, Tot-N, Tol-P, $NO_3$ -N, $PO_4$ –P, Tot-Coliform ជាដើម ។* | នៅក្នុងអាងស្តុកទឹក | រាល់ ៦ ខែ ពេញក្នុងដំណាក់កាលដំណើរការ | DPC និង DoE | ៦០០០០ |
| មជ្ឈមណ្ឌលស្រាវជ្រាវត្រីខ្នាតមធ្យមមួយ ដើម្បីធ្វើអោយមានតុល្យភាពត្រីនៅខ្សែទឹក ខាងលើ និង ខ្សែទឹកខាងក្រោមក្នុងទន្លេទាំងពីរ ។ | តែកមើល មជ្ឈមណ្ឌលស្រាវជ្រាវដំណើរការ យ៉ាងដូចម្តេច? | នៅ មជ្ឈមណ្ឌលស្រាវជ្រាវភ្ញាស់ពូជត្រី | ប្រចាំឆ្នាំក្នុងរយៈពេលដំណើរការ ៥ ឆ្នាំ ដំបូង | ខ័ណ្ឌរដ្ឋបាលជលផល និង DEIA/MoE | ១៣០០ |
| កម្មវិធីទ្រទ្រង់កសិកម្ម សំរាប់អ្នករស់នៅតាមដងទន្លេសេសាន និងស្រែពក ក្នុងប្រទេសកម្ពុជា | តែកមើល កម្មវិធីទ្រទ្រង់កសិកម្មដំណើរការ យ៉ាងដូចម្តេច? | ក្នុងតំបន់គំរោង និងខ្សែទឹកខាងលើ | ប្រចាំឆ្នាំក្នុងរយៈពេលដំណើរការ ៥ ឆ្នាំ ដំបូង | ខ័ណ្ឌរដ្ឋបាលជលផល និង DEIA/MoE | ១៣០០ |

<u>**ចំណាំៈ**</u> ការប៉ាន់ប្រមាណតំលៃខាងលើមិនរាប់បញ្ចូលការចំណាយរបស់ បុគ្គលិក/វិស្វករ របស់ក្រុមហ៊ុនប្រតិបត្តិគំរោងទេ ។